**BBI0082**

# សម្ភាសន៍ជាមួយឈ្មោះ ដួ យ៉ន ភេទប្រុស អាយុ៦៥ឆ្នាំ

មុខងារនៅសម័យខ្មែរក្រហមៈ ប្រធានកងចល័តស្រុក

មុខងារបច្ចុប្បន្នៈ កសិករ

ស្រុកកំណើតនៅភូមិអណ្តូងប្រាំង ឃុំស្រង់ ស្រុកគងពិសី ខេត្តកំពង់ស្ពឺ

សព្វថ្ងៃរស់នៅភូមិដូង ឃុំបឹងរាំង ស្រុកកំរៀង ខេត្តបាត់ដំបង

ថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១១

សម្ភាសន៍ដោយៈ ឡុង ដានី

០១:២៩:៣៨

៤៣ ទំព័រ

ដានី : ចឹងដឹបូងខ្ញុំចង់ស្គាល់ឈ្មោះអ៊ំៗឈ្មោះពេញឈ្មោះអីដែរ?

យ៉ន : បាទ! ខ្ញុំឈ្មោះ ដួ យ៉ន ។

ដានី : ឈ្មោះ ដួ យ៉នហ៎?

យ៉ន : បាទ!

ដានី : អ៊ំអាយុប៉ុន្មានហើយសព្វថ្ងៃ?

យ៉ន : ខ្ញុំ៦០ ចូល៦៥ហើយ ។

ដានី : ៦៥ឆ្នាំ អ៊ំ?

យ៉ន : បាទ!

ដានី : អ៊ំសព្វថ្ងៃរស់នៅក្នុងភូមិឃុំស្រុកអីដែរ?

យ៉ន : យើងនេះ ខ្ញុំនៅម្តុំភូមិដូង ឃុំបឹងរាំង ស្រុកកំរៀង ។

ដានី : ភូមិដូង ឃុំបឹងរាំង ស្រុកកំរៀង ខេត្តបាត់ដំបង ។ ស្រុកកំណើតអ៊ំនៅណាដែរ?

យ៉ន : បាទ! ខ្ញុំនៅភូមិអណ្តូងប្រាំង ឃុំស្រង់ ស្រុកគង់ពិសី ខេត្តកំពង់ស្ពឺ ។

ដានី : ភូមិអណ្តូងប្រាំង ឃុំស្រង់ ស្រុកសំរោងទង?

យ៉ន : ស្រុកគងពិសី ។

ដានី : ស្រុកគងពិសី ខេត្តកំពង់ស្ពឺ ។ ចុះអ៊ំគ្រួសារអ៊ំ គាត់ឈ្មោះអីដែរ?

យ៉ន : ខ្ញុំគ្រួសារគាត់ស្លាប់បាត់ហើយ ។

ដានី : គាត់ស្លាប់អន្តរាល់?

យ៉ន ៖ ស្លាប់នោះ១០ឆ្នាំហើយ ។

ដានី ៖ គាត់ឈ្មោះអីដែរ?

យ៉ន ៖ ត្រកូលគាត់ប៉ែន មិត្ត ។

ដានី ៖ ប៉ែន មិត្ត គាត់ស្លាប់១០ឆ្នាំ គាត់ស្លាប់ដោយសារមូលហេតុអី?

យ៉ន ៖ ស្លាប់លោកក្មួយ គាត់កើតជម្ងឺបេះដូងរីក ។

ដានី ៖ ចុះអ៊ំមានកូនចៅប៉ុន្មាននាក់ដែរ?

យ៉ន ៖ ខ្ញុំកូន៦នាក់លោកក្មួយ ។

ដានី ៖ កូនចៅ៦នាក់ ស្រីប៉ុន្មាន ប្រុសប៉ុន្មាន?

យ៉ន ៖ ស្រី២ ប្រុស៤ ។

ដានី ៖ គាត់ធំៗហើយ?

យ៉ន ៖ បាទ! មាបនគ្រួសារអស់ខ្លះហើយ នៅសល់ៗ២ ។

ដានី ៖ ស្រី២ ប្រុស៤ ។ អ៊ំសព្វថ្ងៃប្រកបមុខរបររកស៊ីធ្វើអីដែរ?

យ៉ន ៖ ខ្ញុំធ្វើស្រែ ធ្វើចំការនឹងលោកក្មួយ ។

ដានី ៖ ធ្វើស្រែផង ធ្វើចំការផង?

យ៉ន ៖ បាទ! ចំការ សំខាន់ចំការ ។

ដានី ៖ សំខាន់ចំការៗដាំអីខ្លះទៅ?

យ៉ន ៖ ចំការហ្នឹងដាំពោត ដាំដំឡូង ។

ដានី ៖ ដាំពោត ដំឡូង បានផលច្រើនទេ?

យ៉ន ៖ បាទ! ធ្វើត្រូវទៅគ្រាន់បានម៉ាដោះស្រាយនឹង ។

ដានី ៖ ចុះអ៊ំឪពុកម្តាយអ៊ំគាត់ឈ្មោះអីខ្លះទៅ?

យ៉ន ៖ ពុកៗស្លាប់អស់រលីង អូ!នៅតែម្តាយ ។ ឪពុកឈ្មោះ សួស យឹន ។

ដានី ៖ បាទ! ឈ្មោះអី?

យ៉ន ៖ សួស ត្រកូលគាត់ សួស យឹន ។

ដានី ៖ សួស យឹន?

យ៉ន ៖ បាទ!

ដានី ៖ សួស យឹន គាត់ស្លាប់ឆ្នាំណាទៅ?

យ៉ន ៖ ស្លាប់តាំងពីឆ្នាំ១៩៧៥ គ្រាន់បែកភ្នំពេញហើយនឹង ។

ដានី ៖ គាត់ស្លាប់ដោយសារអីទៅ?

យ៉ន ៖ ស្លាប់កាលនឹងគាត់ទៅដឹកសម្ភារៈយោធា បែបខ្យល់តាមមើលទៅជាភាគរុះគាត់អាសន្នរោគទៅ ។

ដានី ៖ ចុះម្ដាយ?

យ៉ន ៖ ម្ដាយអ៊ុក គា ។

ដានី ៖ អ៊ុក គា សព្វថ្ងៃគាត់នៅរស់?

យ៉ន ៖ បាទ! នៅ ។

ដានី ៖ គាត់អាយុប៉ុន្មាន?

យ៉ន ៖ ព្រះជន្មនោះ៩០ហើយលោកក្មួយ ។

ដានី ៖ អូ! អាយុវែងមែនទែន ។

យ៉ន ៖ បាទ! ៩០ ។

ដានី ៖ ៩០ គាត់រស់នៅទៅរាល់ថ្ងៃ?

យ៉ន ៖ បាទ! នៅជាមួយខ្ញុំនឹង ភូមិដូង ។

ដានី ៖ អ៊ំទៅយកគាត់មកនៅជាមួយ?

យ៉ន ៖ បាទ!

ដានី ៖ ចុះអ៊ំមានបងប្អូនបង្កើតប៉ុន្មាននាក់ដែរ?

យ៉ន ៖ ខ្ញុំបងប្អូនបង្កើតនៅសល់៥នាក់ ។

ដានី ៖ ទាំងអស់ប៉ុន្មាននាក់?

យ៉ន ៖ ទាំងអស់៦នាក់ ។

ដានី ៖ ៦នាក់ ស្រីប៉ុន្មាន ប្រុសប៉ុន្មាន?

យ៉ន ៖ ប្រុស២ នៅសល់ស្រី៣ ។

ដានី ៖ ចឹងស្លាប់អស់ប្រុស ស្លាប់?

យ៉ន ៖ ស្លាប់ស្រី១ ។

ដានី ៖ អ៊ំកូនទីប៉ុន្មាន?

យ៉ន ៖ ខ្ញុំទី១ ។

ដានី ៖ បងគេបង្អស់?

យ៉ន ៖ បាទ! បងគេបង្អស់ ។

ដានី ៖ អ៊ំកាលពីក្មេងៗ អ៊ំបានរៀនសូត្រដល់ណា?

យ៉ន ៖ បាទ! ខ្ញុំរៀនពីជំនាន់នឹង សាលាបឋមបំពេញវិជ្ជាថ្នាក់ទី៧ ។

ដានី ៖ ថ្នាក់ទី៧ពីសង្គម?

យ៉ន ៖ បាទ!

ដានី ៖ នៅសាលាណាហ្នឹង?

យ៉ន ៖ នៅសាលាអង្គតាភេម ភ្នំស្រង់ ។

ដានី ៖ តាភេម ភ្នំស្រង់ ។ កាលនឹងអ៊ំឈប់ឆ្នាំណាទៅដល់ថ្នាក់ទី៧ហ្នឹង?

យ៉ន ៖ ខ្ញុំឈប់ពីឆ្នាំណា ៦០ ៦៨ហើយលោកក្មួយ ។

ដានី ៖ ៦៨?

យ៉ន ៖ បាទ!

ដានី ៖ ឈប់ហើយធ្វើអីទៀតទៅ?

យ៉ន ៖ ឈប់ហើយខ្ញុំពឹតតែធ្វើស្រែនៅជាមួយម៉ែនៅឡើយនោះ ឈប់រៀនហើយខ្ញុំបួសទៀត ។

ដានី ៖ បួសបានប៉ុន្មានឆ្នាំ?

យ៉ន ៖ បាទ! បួសហ្នឹងចំនួនតែមួយវស្សាទេ បើយើងគិតទៅ២ឆ្នាំទៅ យើងគិតទៅតែម៉ាវស្សា ។

ដានី ៖ តែម៉ាវស្សាទេ?

យ៉ន ៖ បាទ!

ដានី ៖ បួសម៉ាវស្សានៅវត្តណា?

យ៉ន ៖ បួសនៅហ្នឹង នៅវត្តអង្គតាភេមនឹង ។

ដានី ៖ តាភេមភ្នំស្រង់?

យ៉ន ៖ បាទ!

ដានី ៖ ដល់ពេលសឹកមកវិញ?

យ៉ន ៖ សឹកមកវិញអាហ្នឹងចាប់ផ្ដើមធ្វើៗស្រែវិញហើយ ។

ដានី ៖ ធ្វើស្រែជាមួយឪពុកម្ដាយ ឬក៏?

យ៉ន ៖ បាទ! ធ្វើស្រែជាមួយឪពុកម្ដាយ ។

ដានី ៖ ជាមួយ?

យ៉ន ៖ ជួយការងារគាត់ ។

ដានី :	បាទ! អ៊ីរៀបការឆ្នាំណា?

យ៉ន :	ខ្ញុំការឆ្នាំ១៩៦៨ ។

ដានី :	ចឹងគ្រួសារអ៊ីគាត់អ្នកស្រុកណា?

យ៉ន :	បាទ! នៅជាមួយគ្នាហ្នឹង ក្នុងភូមិជាមួយគ្នា ឃុំជាមួយគ្នា ។

ដានី :	ជាមួយគ្នា យ៉ាងម៉េចឪពុកម្ដាយរៀបចំឲ្យ ឬក៏អ៊ី?

យ៉ន :	បាទ! ឪពុកម្ដាយរៀបចំឲ្យលោកក្មួយ ។

ដានី :	ចុះបន្ទាយពីរៀបការហើយធ្វើអីទៀត?

យ៉ន :	បន្ទាប់ពីរៀបការហើយនឹងដល់ពេលសង្គ្រាមវិញទៀតហើយលោកក្មួយ ។ ឆ្នាំ៧០ហើយ ថា៦៨ ៧០បណ្ដោយ ។

ដានី :	រៀបការហើយធ្វើស្រែបានម៉ា?

យ៉ន :	បាទ! ធ្វើបានម៉ាឆ្នាំជាងតិច មិនទាន់រកស៊ីអីផងទេ ។

ដានី :	ដល់ពេលឆ្នាំ៧០ពេលរដ្ឋប្រហារហ្នឹងយ៉ាងម៉េចទៅ?

យ៉ន :	រដ្ឋប្រហារហ្នឹងមានការផ្សារធ្វើនឹងគេ ប៉ុរ៉ាំ ។

ដានី :	បានន័យថាឆ្នាំ៧០ អ៊ីយ៉ាងម៉េច អ៊ីចូលធ្វើការជាមួយខាងកងរំដោះ?

យ៉ន :	បាទ! ហ្នឹងហើយ កាលហ្នឹងគេថាយៀកកុង១ ។

ដានី :	យ៉ាងម៉េច អ៊ីអាចជួយរៀបរាប់ខ្ញុំកន្លែងហ្នឹងច្បាស់?

យ៉ន :	ជំនាន់ហ្នឹងពួកហាណូយ១ចុះមករៀបចំជាកម្មាភិបាល តាមភូមិតាមអីហើយ ។

ដានី :	បាទ១ យៀកកុងគេមករៀបចំ?

យ៉ន :	បាទ!

ដានី :	ដល់គេមករៀបចំកម្មាភិបាលតាមភូមិនឹងយ៉ាងម៉េច?

យ៉ន :	យើងហ្នឹងគេឲ្យធ្វើឈ្លបហើយ ឈ្លបភូមិ ឈ្លបឃុំ ដើរធ្វើការជាមួយគេ ។

ដានី :	អ៊ីស្ម័គ្រចិត្តធ្វើ?

យ៉ន :	បាទ! ចុះបើទៅនោះ ខ្ញុំចូលធ្វើទាហាននឹងគេ ប្រហែលជាបាន២-៣ថ្ងៃ មើលទៅយៀកកុងដុត១ ខ្ញុំនៅ..... ។

ដានី :	ដល់ពេលអ៊ីកាលនឹងឆ្នាំ៧០ម៉ងចូល១?

យ៉ន :	បាទ! ៧០ ។

ដានី :	យើងចូលដំបូងចូលធ្វើឈ្លប?

យ៉ន ៖ បាទ!

ដានី ៖ ធ្វើឈ្លបនៅតាមណា នៅតាមណា នៅតាមភូមិ?

យ៉ន ៖ ឈ្លបភូមិៗឡើងទៅឃុំ។

ដានី ៖ បាទ! មុនដំបូងនៅភូមិ?

យ៉ន ៖ គេឲ្យយើងការពារភូមិ មានគេយ មានអី ចារកម្ម។

ដានី ៖ ជាមួយខាងយៀកកុង?

យ៉ន ៖ បាទ! សេ.អ៊ី.អា អាមេរិចអី ជំនាន់ហ្នឹង។

ដានី ៖ នៅភូមិណា?

យ៉ន ៖ នៅភូមិអណ្ដូងប្រាំង ឃុំស្រង់ ភ្នំស្រង់ គេធ្វើនៅតែភូមិយើងហ្នឹង។

ដានី ៖ ធ្វើនៅភូមិបានរយៈពេលប៉ុន្មាន បានឡើងមកឃុំទៀត?

យ៉ន ៖ បាទ! ធ្វើ អីភូមិយូរដែរលោកក្មួយ។

ដានី ៖ យូរប្រហែលប៉ុន្មាន?

យ៉ន ៖ បានគេឲ្យឡើងមកឃុំៗហ្នឹងនៅក្នុងភូមិហ្នឹងដដែល មន្ទីរភូមិ ហើយនឹងឃុំនៅជាប់គ្នា។ ធ្វើការភូមិផង ដល់ថ្ងៃជ្រើសរើសទៅធ្វើការឃុំ យើងឡើងទៅជាមួយកងទ័ព។

ដានី ៖ ហ្នឹងស្អីគេ គេហៅស្អីគេ?

យ៉ន ៖ អាហ្នឹងឈ្លប យើងឈ្លប គេកងទ័ព បាទ!ទៅជាមួយគេដែរ។

ដានី ៖ ទៅណា?

យ៉ន ៖ ហ្នឹងយើងក៏ត្រៀមចាំឡើងមក។

ដានី ៖ ខ្លាចៗខាងណាឡើងមក?

យ៉ន ៖ ទាហាន។

ដានី ៖ ទាហានលន់ នល់?

យ៉ន ៖ បាទ!

ដានី ៖ នៅណា ឡើងនៅណា?

យ៉ន ៖ ហ្នឹងយើងគ្រាន់ឥឡូវប៉ុស្តិ៍ ប៉មគេវានៅឃុំស្រង់ នៅសាលាស្រុកស្រង់ គេធ្វើបន្ទាយគេនៅហ្នឹង។

ដានី ៖ នៅជិតគ្នាចឹង?

យ៉ន ៖ បាទ! ជិតគ្នាដែរ ដី៦គីឡូ។

ដានី ៖ ឃុំស្រង់ ហើយសាលាស្រុកជិតគ្នា?

យ៉ន ៖ បាទ!

ដានី ៖ ហើយម៉េចទៅ អ៊ំធ្វើឈ្លបឃុំនៅឃោមជាមួយភ្នំស្រង់ដល់ពេលណា?

យ៉ន ៖ ដល់ពេលដែលឆ្នាំ៧០ទាល់តែដល់បែកហ្នឹងលោកក្អួយ បែក៧៥ធ្វើតែឈ្លបៗនេះដើរវែងណាស់ ឲ្យតែសមរភូមិខេត្តកំពង់ស្ពឺហ្នឹង គឺត្រូវដើរជាប់ តាមកងទ័ព ភារកិច្ចយើងសែងរបួស សែងអីហ្នឹងស្នាក់ការ ។

ដានី ៖ ដើររហូត ចឹងអ៊ំធ្វើឈ្លបហ្នឹងរហូតដល់ឆ្នាំ៧៥ ដើរតាមកងទ័ព?

យ៉ន ៖ បាទ! ធ្វើទល់៧៥ ។

ដានី ៖ ចុះអ៊ំស្រី?

យ៉ន ៖ គាត់នៅការផារក្រោយខាងបន្ទុបធ្មើតផល ។

ដានី ៖ បាទ! ប៉ុន្តែគាត់ចូលជាមួយខាងរំដោះដែរ?

យ៉ន ៖ បាទ! នៅហ្នឹងគ្នា ។

ដានី ៖ កាលហ្នឹងអ៊ំមានកូនមានចៅដែរ?

យ៉ន ៖ ខ្ញុំកាលហ្នឹងមានកូនមួយហើយ ។

ដានី ៖ ដល់ពេលយើងដើរជាមួយកងទ័ព ហើយសែងរបួសសែងអីចឹង ហើយបែកពីគ្រួសារយូរៗ?

យ៉ន ៖ បាទ! ទៅសមរភូមិមួយៗ បើវ៉ៃត្រូវបែកក៏វាឆាប់ បើមិនបែក វ៉ៃត្រូវត្រង់សេរក៏វាយូរខ្ទង់ម៉ាអាទិត្យអីទៅ ។

ដានី ៖ ដល់ពេលយើងសែងរបួសៗកងទ័ពខាងទ័ពរំដោះហ្នឹង ទៅខាងណាទៅ?

យ៉ន ៖ យើងសែងទៅសមរភូមិយើងខាងក្រោយ កន្លែងមានសុវត្ថិភាព ។

ដានី ៖ នៅណាទៅ?

យ៉ន ៖ ហ្នឹងនៅក្នុងខេត្តកំពង់ស្ពឺហ្នឹងដែរ ។

ដានី ៖ ម្តុំណា?

យ៉ន ៖ យើងនៅនោះចំការក្រោយៗយើង គេមិនប្រាប់ឲ្យយើងដឹងដែរ ដល់យកទៅដាក់មន្ទីរពេទ្យក្រោយ ។ ថាត្រូវរបួស ទៅមន្ទីរពេទ្យក្រោយ ។

ដានី ៖ ដល់ពេលបែកឆ្នាំ៧៥ ៗហើយយ៉ាងម៉េចទៀតទៅ?

យ៉ន ៖ បែកឆ្នាំ៧៥ហ្នឹងការរៀបចំដំនាន់ហ្នឹងគេហៅអន្តការៗ បង្កើតជាក្រុមកងចល័តៗ ទ័ពគឺរំលាយអស់ហើយ អត់មានកងទ័ពប្រដាប់អាវុធអីទៀតទេ គឺគិតតែពីដឹកប្រព័ន្ធប្រឡាយ ហើយនឹងប្រព័ន្ធប្រឡាយ គេរៀបចំជាកងចល័តៗ កងចល័តនឹងវាមាន២ប្រភេទ មួយចល័តស្រុក ចល័តតំបន់ រៀបចំដូចកងទ័ពៗ ហើយអាហ្នឹងរៀបដឹកព្រែកប្រព័ន្ធប្រឡាយហើយៗ

ដានី ៖ ដល់ពេលហ្នឹង អ៊ំមកធ្វើអីវិញ?

យ៉ន ៖ ខ្ញុំទៅហ្នឹងនៅតែកងចល័តហ្នឹងៗ

ដានី ៖ អ៊ំមកកងចល័ត គេឲ្យអ៊ំគ្រប់គ្រងកងចល័ត?

យ៉ន ៖ បាទ!

ដានី ៖ គ្រប់គ្រងកងចល័ត គេហៅចល័តអីគេ?

យ៉ន ៖ អាហ្នឹងកងចល័តស្រុកៗ ៗ

ដានី ៖ បាទ! ប្រធានកងចល័តស្រុក?

យ៉ន ៖ បាទ!

ដានី ៖ ស្រុកអីគេ ស្រុក?

យ៉ន ៖ ស្រុកហ្នឹងមកនៅឯងកំពង់ស្ពឺនេះហើយៗ

ដានី ៖ ស្រុកអី មិនមែនស្រុកគងពិសីទេ?

យ៉ន ៖ មិនមែនគងពិសីហើយ ប៉ុនឥឡូវគេកាត់ៗ

ដានី ៖ គេហៅស្រុកលេខប៉ុន្មានៗ កាលហ្នឹង?

យ៉ន ៖ កាលមុនគេច្រើនប្រើតំបន់៣២ៗ ៗ

ដានី ៖ ស្រុកប៉ុន្មានទៅក្នុងតំបន់៣២ ស្រុកលេខប៉ុន្មាន?

យ៉ន ៖ អឺ! មិនដឹងលេខប៉ុន្មានទៀតហើយៗ

ដានី ៖ ប៉ុន្តែបើក្នុងស្រុកអីគេទៅ គេហៅស្រុក?

យ៉ន ៖ កាលហ្នឹងយើងនៅគងពិសីនៅឡើយទេលោកក្មួយ ម្តុំយើងនេះអែបវត្តអំពែភ្នំនេះលោកក្មួយៗ

ដានី ៖ បាទ! លេខតំបន់៣២ៗ ភូមិភាគអីគេ?

យ៉ន ៖ ទេ! អាហ្នឹងគេហៅ៣២ៗ

ដានី ៖ ៣២ តំបន់៣២?

យ៉ន ៖ បាទ! ៣២ ។

ដានី ៖ នៅក្នុងភូមិភាគនិរតី ឬក៏នៅភូមិភាគ?

យ៉ន ៖ នៅនិរតីទេ បាទ! ភូមិភាគនិរតី ។

ដានី ៖ ភូមិភាគនិរតី ។ យើងដូចជាកងចល័ត ប្រធានកងចល័តគេធ្វើការងារអីខ្លះទៅ?

យ៉ន ៖ កងចល័តដូចខ្ញុំបានជម្រាប កងចល័តនឹងមានភារកិច្ចជីកតែប្រឡាយ ហើយនឹងទប់ទំនប់ វែកដីហ្នឹង ។ កាលហ្នឹងក្មៀវចេញអី មកមើល ។ កន្លែងណាទប់ៗខ្ពស់ៗណាស់ ។

ដានី ៖ ជីកប្រឡាយ វែកដី?

យ៉ន ៖ បាទ! ជីកប្រឡាយ កន្លែងណាទំនប់ៗ កន្លែងណាជីកៗ ត្រូវទប់ទំនប់ម៉ង មើលស្ថានភាពដី ។

ដានី ៖ បាទ! ក្នុងកងចល័តគ្នាច្រើន?

យ៉ន ៖ បាទ! អឺ!ចល័តរៀបចំជាកងវរៈរបស់វាដូចកងទ័ព រៀបពេញទាំងអស់ ។

ដានី ៖ បាទ! គេហៅរៀបយ៉ាងម៉េចទៅ?

យ៉ន ៖ បាទ! មានកងហា មានកងរយអីចឹងទៅ ។

ដានី ៖ រហូតដល់អីទៅម៉ាក្រុម?

យ៉ន ៖ ម៉ាវរៈគេចឹងទៅ ម៉ាកងវរៈនឹង៣០០-៤០០នាក់ទៅ ។

ដានី ៖ កងវរៈ គេហៅវរៈអីគេ វរៈសេនាតូច វរៈសេនាធំ?

យ៉ន ៖ ម៉ាវរៈសេនាតូច ឡើងម៉ាវរៈសេនាធំ ក្រៅពីហ្នឹងកងពល គ្រប់គ្រងទាំងអស់ ។

ដានី ៖ បាទ! ចឹងកាលហ្នឹងម៉ាស្រុកហ្នឹង បានដល់វរៈសេនាធំ?

យ៉ន ៖ បាទ! គេរៀបចំវាប្រមូលមកក្នុងតំបន់ចឹងម៉ង យកពីស្រុកនេះខ្លះ ម៉ាស្រុកនោះខ្លះៗ ។

ដានី ៖ តែអ៊ំប្រធានកងចល័តស្រុក ឬតំបន់៣២?

យ៉ន ៖ ខ្ញុំនៅស្រុកទេលោកក្មួយ ខ្ញុំឋានៈស្មើហ្នឹងកងហាទេ បើខ្ញុំនៅជាមួយលោកចៅហ្វាយស្រុកដែរ ។

ដានី ៖ គេហៅចៅហ្វាយស្រុកដែរ?

យ៉ន ៖ ខ្ញុំគេឲ្យនៅចាំទំនប់ ។

ដានី ៖ ចៅហ្វាយស្រុកណា?

យ៉ន ៖ អូ! ស្លាប់អស់ហើយលោកក្មួយអើយ ។

ដានី ៖ ប៉ុនគាត់ឈ្មោះអីគេ?

យ៉ន ៖ គាត់មិនស្គាល់ត្រកូលគាត់............ខ្ញុំរត់យកវ៉ៃចោលបាត់ទៅ ។

ដានី ៖ បាទ! ហៅឈ្មោះតាអីទៅ?

យ៉ន ៖ គាត់ឈ្មោះអីប៉ន ស្គាល់តែឈ្មោះគាត់ ត្រកូលខ្ញុំមិនស្គាល់ ។

ដានី ៖ ស្គាល់ឈ្មោះគេហៅតាប៉នៗ ?

យ៉ន ៖ បាទ! គាត់នៅខាងរការធំ ។

ដានី ៖ រការធំនៅខាង?

យ៉ន ៖ រការធំយើងបែបកំពត ចេញពីនឹងមកត្រឹមម៉ា ។

ដានី ៖ គាត់ឲ្យអ៊ំនៅជាមួយគាត់?

យ៉ន ៖ បាទ!

ដានី ៖ គាត់គណៈស្រុកដែរ?

យ៉ន ៖ បាទ!

ដានី ៖ អ៊ំគ្រប់គ្រងកងចល័ត គាត់គ្រប់គ្រងស្រុក?

យ៉ន ៖ គាត់គ្រប់គ្រងស្រូវ អង្ករ អីយ៉ាំង ។ ហើយដល់បាក់ទំនប់ហ្នឹង គេចោទថាគាត់ក្បត់ ។ ខ្ញុំនៅយាមតែម៉ាភ្លែត ខ្ញុំរាយការណ៍ដែរ ដើរចូលអន្លង់ ។

ដានី ៖ បាក់ទំនប់ម៉េច ទំនប់ណា?

យ៉ន ៖ ទំនប់ដែលយើងជិតវត្តអំពែភ្នំៗ ។

ដានី ៖ បាក់ឆ្នាំណា?

យ៉ន ៖ បាក់ហ្នឹងពីឆ្នាំ៧៦ ៗ បាទ! ៧៦ ។

ដានី ៖ ដល់បាក់ទៅយ៉ាងម៉េច?

យ៉ន ៖ បាក់ទៅគេមានតេអូ លិចផ្លូវ ពីកំពង់ស្ពឺទៅវត្តអង្គ ។

ដានី ៖ លិចផ្លូវ?

យ៉ន ៖ លិចអស់ស្រូវម៉ាជួរហ្នឹងទាំងអស់ ហើយចឹងគេថាគាត់ក្បត់ ។

ដានី ៖ ក្បត់ហើយគេធ្វើម៉េចទៅ?

យ៉ន ៖ ចាប់គាត់ដាក់ឃុំឃាំង ។

ដានី ៖ ឃុំឃាំងនៅណា?

យ៉ន ៖ ឃុំឃាំងនៅកាលហ្នឹងគេមិនទាន់យកដាក់នៅនេះទេ គេយកទៅដាក់នៅវត្តអង្គនៅឡើយៗ វត្តអង្គកំពង់ត្រាំយើងហ្នឹង ។

ដានី : បាទ! ហើយម៉េចទៀត?

យ៉ន : ហើយដល់គាត់តូចចិត្ត គាត់ខ្មាស់គេហ៊ានៈប៉ុននឹងដែរ ដល់យកមកដាក់គុក ដាក់គាត់អោបបង្អួចចេះ គាត់ចង-កជាប់នឹងបង្អួចនឹងម៉ង ។

ដានី : គណៈតំបន់ចាប់គាត់?

យ៉ន : បាទ! គណៈតំបន់ចាប់ ។

ដានី : ពីណាគេគណៈតំបន់?

យ៉ន : ទេ! សុទ្ធតែមកពីក្នុងមក ខ្ញុំ ។

ដានី : អត់ស្គាល់ឈ្មោះ?

យ៉ន : ហ៎! ចាប់កាលហ្នឹងប្រហែលម៉ោង៨ ខ្ញុំរៀបទៅហូបបាយ ។

ដានី : ខែប៉ុន្មានគេចាប់គាត់ ខែប៉ុន្មានដែលបាក់ទំនប់?

យ៉ន : ខ្ញុំរៀបចំ ជិតដើមឆ្នាំហើយលោកក្មួយ ។

ដានី : ដើមឆ្នាំ៧៦ហ្នឹងម៉ង?

យ៉ន : បាទ! ដើមឆ្នាំហើយ ។

ដានី : បានតិចហ្នឹង ទើបបែកបានតិច?

យ៉ន : បាទ!

ដានី : ទើបបែកបាន៤-៥ខែ ។ ចុះអ៊ំដូចកងចល័តៗហ្នឹងអាយុប្រហែលប៉ុន្មាន ចន្លោះពីប៉ុន្មានទៅ ប៉ុន្មាន?

យ៉ន : ខ្ញុំ ។

ដានី : អត់ទេ ក្នុងកងចល័តរបស់អ៊ំ?

យ៉ន : ក្នុងកងចល័តអាយុមិនជាច្រើនប៉ុន្មានលោកក្មួយ មាន២០លើស នឹងកំរមានពីណាអាយុ ៣០ ។ ហើយខ្ញុំកាលហ្នឹងអាយុទើប២៦អីហ្នឹង ។

ដានី : ចុះអ៊ំ កាលហ្នឹងដូចកងចល័តមានអ្នកស្រុកអ្នកភូមិនៅក្នុងនឹង ឬយ៉ាងម៉េច?

យ៉ន : បាទ?

ដានី : និយាយថា អ្នកដែលសមាជិកកងចល័តរបស់អ៊ំហ្នឹង កូនអ្នកស្រុកអ្នកភូមិនៅក្នុងស្រុក?

យ៉ន : បាទ! សុទ្ធតែកូនអ្នកស្រុកអ្នកភូមិ ។

ដានី : ហើយមានអ្នកជម្លៀសមកដែរអត់?

យ៉ន : បាទ?

ដានី ៖ កូនអ្នកប្រជាជន១៧មេសា?

យ៉ន ៖ ក៏មានដែរ ។

ដានី ៖ មានដែរ?

យ៉ន ៖ បាទ! ប្រវត្តិរូបគេល្អហ្នឹង គេចូលជាមួយយើងដែរ ចូលកាប់ជាមួយគ្នាធ្វើជាមួយគ្នា ។

ដានី ៖ ចុះកាលហ្នឹងយើងធ្វើ ដូចថាអ៊ំជាអ្នកចាត់ចែងការងារឲ្យធ្វើ ឬក៏មានគេចាត់ចែងពីលើ?

យ៉ន ៖ មានគេចាត់ពីលើ យើងឋានៈយើងគ្រាប់បានក្តាប់បានប៉ុន្មាន៣០-៤០នាក់ហ្នឹងទេ ។

ដានី ៖ ហើយពីលើគេអ្នកចាត់ចែង?

យ៉ន ៖ ពីលើគេអ្នកចាត់ចែងការងារឲ្យយើង យើងគ្រាន់គ្រប់គ្រងកម្លាំងយើងមកដាក់ចឹងរួចទៅមកគ្រប់គ្រង មើលការខុសត្រូវ ។ ហើយគេគ្រប់គ្រងពីលើយើងទៀតមក មានគេកងវរយ គេបញ្ជាលើយើងទៅទៀតមក ។ ហើយដល់ឥឡូវគេឡើងទៅណា កងវរយឡើងទៅណាវា ដាប់ទាំងយើងទាំងអីនឹងទៅមកជាមួយគេទៅ ។

ដានី ៖ គេធ្វើការគេដូចថាលើកទំនប់ ជីកប្រឡាយ រែកដីអីហ្នឹង ។ ហើយយើងធ្វើការពីម៉ោងប៉ុន្មានដល់ម៉ោងប៉ុន្មាន?

យ៉ន ៖ បាទ! ពេលព្រឹកហ្នឹងម៉ោង យើងចុះប្រហែលជាម៉ោង៦-៧ដែរហ្នឹង យី!ជំនាន់ហ្នឹងដូចជា ជួនណាម៉ោង៥ លោកក្មួយ ហ៎!ម៉ោង៤គោះជួងហើយៗ ដល់ម៉ោង១១សម្រាក ឈប់ ហូបបាយ ។

ដានី ៖ ដល់ពេលម៉ោងប៉ុន្មានចូលវិញ?

យ៉ន ៖ ម៉ោង១ ជួនណាម៉ោង២តាមពេលថ្ងៃ ។

ដានី ៖ ដល់ពេលម៉ោងប៉ុន្មានបានចប់?

យ៉ន ៖ ដល់ថ្ងៃល្ងាចម៉ោង៥ ។

ដានី ៖ ល្ងាចម៉ោង៥ ។ ចុះយប់មានធ្វើទៀតអត់?

យ៉ន ៖ បាទ! យប់អត់ធ្វើទេ មានពេលដូចថាកុនពេលអាចធ្វើ បើថាគេសំរុកឲ្យហើយថាធ្វើយប់ យើងធ្វើយប់ អត់ទេយើង ។

ដានី ៖ គេហូបចុកម៉េចដែរ?

យ៉ន ៖ អឺ! ជំនាន់ហ្នឹងលោកក្មួយខ្វះខ្សោយ ។

ដានី ៖ ខ្វះខ្សោយម៉េចទៅ?

យ៉ន ៖ បាទ! ព្រោះកាលហ្នឹងភ្ញាម១ចេះ ស្រូវអង្ករក៏មិនសូវមាន ហូបតែមួយ ដួនណាពោតចឹង ទៅ ដំឡូងចឹងទៅ ។

ដានី ៖ បាយ?

យ៉ន ៖ បាទ!

ដានី ៖ បាយលាយដំឡូង?

យ៉ន ៖ បបរ ម៉េចបានបាយ បបរទេ ។

ដានី ៖ ឆ្អែតដែរ ហូបឆ្អែតកាលហ្នឹង?

យ៉ន ៖ អឺ! សុទ្ធជិនាន់វាស់ម៉ង ម៉ាកា១យើង ។

ដានី ៖ អឹហូបជាមួយដែរ ឬក៏អឹហូបផ្សេង?

យ៉ន ៖ ឲ្យហូបជាមួយគ្នាហ្នឹង ។

ដានី ៖ ចុះយើង?

យ៉ន ៖ យើងមកតាមកងយើងទៅ ។

ដានី ៖ ហូបចឹងយើងមានកម្លាំងណាធ្វើការ?

យ៉ន ៖ ដឹង ធ្វើម៉េចលោកក្មួយ បើសិនជាយើងយកទៅឲ្យឆ្អែតមិនដឹងជាបានមកពីណា បើគេធ្វើ តែប៉ុនហ្នឹង បើសម្លគេចេះស្លច្រើនម៉ាខ្ទះ១ ដល់អង្ករវាដោះស្រាយវាមិនចេញ ។ មានតែ ដំឡូង ហើយនឹងពោត បើបានពោតគេដាំបាយ ដួនកាលគេកិនគ្រាប់ទាល់តែធ្វើស្រូវបាន ខ្លួនឯង បាន១ហូបវិញ ។ បានហូបវិញ ខ្ញុំមកដល់នេះពិបាកណាស់ ។

ដានី ៖ ចឹងអឹកាលហ្នឹងដូចថាយើងមានកូនអ្នកស្រុក អ្នកភូមិ ឬក៏ប្រជាជន១៧មេសាអីចឹង ចុះគេ មានខាងលើ១ គេមានប្រាប់អឹថាយើងត្រូវបែងចែក ប្រជាជនចាស់ ប្រជាជនថ្មីអីយ៉ាង ម៉េច គេមានប្រាប់ដែរអត់?

យ៉ន ៖ អត់ទេលោកក្មួយ ជំនាន់ហ្នឹង ដឹងមានតាមដានអីកាលហ្នឹង ពីមុនដំបូងបង្អស់កាលយើងអ្នក មូលដ្ឋានចាស់ ។ ឥឡូវអង្គការ គេប្រាប់ថាភ្នំពេញគេគង់តែបែកទេ កម្លាំងហ្នឹងពួកមិត្តឯង ទាំងអស់ហ្នឹងគេទទួលមិនគ្រប់ មនុស្សគេមកច្រើន អត់ស្រូវស៊ី ។ ចឹងទៅគេខទាហរណ៍ខ្ញុំ ម៉ាគ្រួសារចឹង គេដាក់ឲ្យខ្ញុំ២- ៣គ្រួសារឲ្យខ្ញុំដោះស្រាយឲ្យគេហូប បញ្ជូនមកភ្នំពេញភ្ញាម នោះ ។ នោះគេនៅមើលខ្ញុំ ស្រូវខ្ញុំកិនហូបទៅ តែម្ហូបអាហារនឹងមិនមានទេ មានតែស្រូវ អាហ្នឹងគេដើរដាក់តាមគ្រួសារយើង ។

ដានី ៖ គេអត់មានប្រាប់យើង ឧបមាថាប្រជាជនថ្មីពួកថ្មីហ្នឹង ពួករស់នៅកន្លែងលន់ នល់ យើងត្រូវតែកុំទុកចិត្តពួកហ្នឹង យើងត្រូវតាមដានយ៉ាងម៉េច ហើយប្រជាជនចាស់យើងមានបែងអ្នក វណ្ណៈ?

យ៉ន ៖ អានេះគេដាក់ថា នែក! លោកក្មួយ ថាឲ្យយើងមើលសកម្មភាពមនុស្ស ឲ្យយើងមើលសកម្មភាពតាមដាន ឲ្យយើងពិនិត្យមើលថា តែភាគច្រើនគ្មានមកមិនមានបញ្ហាអីផង តាមអំពើ ហើយនៅពេលវេលាតិច បាននៅតែម៉ាខែហ្នឹង គេគិតចាប់បញ្ជូនទៀតមក មនុស្សវាច្រើនពេក ។

ដានី ៖ គេបញ្ជូនថ្មីៗមកទៀត?

យ៉ន ៖ បាទ! បញ្ជូនឡើងមកយើង បាត់ដំបងវិញហើយ ។

ដានី ៖ ចុះអ៊ំកាលពីបាក់ទំនប់ គេចាប់គណៈស្រុកឈ្មោះប៉ន់ហើយ ចុះអ្នកផ្សេងៗទៀតគេមានចាប់ទេ?

យ៉ន ៖ អ្នកផ្សេងទៀត គេថាអត់មានរឿងអីក៏គេមិនចាប់ ចាប់តែមួយហ្នឹង ។

ដានី ៖ ចាប់តែមួយ?

យ៉ន ៖ តែមិនដឹងថាគេក្បត់រឿង ខ្ញុំមិនដឹង ប៉ុនមូលហេតុគេថាមកពីបង្ខំឲ្យបាក់ទំនប់ ។

ដានី ៖ តែអ៊ំអត់អីទេ រួចខ្លួន?

យ៉ន ៖ ខ្ញុំនៅយាមហ្នឹង ខ្ញុំរត់ទៅផ្ទះបាត់ ក៏គេប្រមូលកម្លាំងទាំងយប់ហ្នឹង មកធ្វើទាំងយប់ហ្នឹងដឹកតាំងពីកំពង់ស្ពឺមក អាបាវខ្សាច់បាវអីហ្នឹងយកមកទប់ៗឯណាឈ្មុះ បើដល់បាក់ ។

ដានី ៖ ចុះសមាជិកកងចល័តអ៊ំ កាលអ៊ំនៅគ្រប់គ្រងនៅហ្នឹងអត់មានគេចាប់ អត់មានគេសម្លាប់អីដែរអត់?

យ៉ន ៖ បាទ! អត់ទេលោកក្មួយ ។

ដានី ៖ អត់ទេនោះ ។ ចុះដល់ឆ្នាំណាដែរ អ៊ំថាផ្លាស់មកបាត់ដំបង?

យ៉ន ៖ ខ្ញុំមកឆ្នាំ៧៧ ខែ៦ ។

ដានី ៖ ខែ៦ ឆ្នាំ៧៧?

យ៉ន ៖ បាទ!

ដានី ៖ ចឹងអ៊ំនៅធ្វើប្រធានកងចល័តនឹងរហូតដល់ខែ៦ ឆ្នាំ៧៧ដែរ?

យ៉ន ៖ បាទ! ហ្នឹងខ្ញុំនៅកំពុងវែកដី គេទៅប្រាប់ខ្ញុំ ហ្នឹងលោកមេឃុំនៅឃុំស្រង់ ម៉ោង១២ ១១ ខ្ញុំកំពុងមុជទឹកវែកដីទំនប់ ទៅមេឃុំបើកម៉ូតូមកថា«បងឯងត្រូវផ្លាស់ទៅពាយ័ព្យ ទៅរៀបចំ ខ្លួនទៅ មិនបាច់ទេ ទៅសម្រាន្តផ្ទះទៅ មិនបាច់សម្រាន្តនេះទេ» ។

ដានី ៖ ផ្លាស់មកទាំងអស់គ្នា ទាំងគ្រួសារ?

យ៉ន ៖ បាទ! មកទាំងគ្រួសារ ទាំងម្ដាយទាំងអីទាំងអស់ខ្ញុំ មកបានប្អូនម្នាក់ទៀត ។

ដានី ៖ គេប្រាប់ថាប៉ុននឹង?

យ៉ន ៖ បាទ!

ដានី ៖ មានសំបុត្រ បញ្ជាថាត្រូវចាត់តាំងឈ្មោះអីមកពាយ័ព្យមានអត់?

យ៉ន ៖ អត់មានទេ គេគ្រាន់តែណែនាំយើងឲ្យទៅក្រោយ «មិនភ័យទេ ខ្ញុំគ្មានយកទៅវៃចោល» «បើខុសអីប្រាប់ថាខុស» ខ្ញុំថាចឹង«ព្រោះខ្ញុំអ្នកធ្វើ» ខ្ញុំថា«ខុសប្រាប់ថាខុស»ខ្ញុំថាចឹង ខ្ញុំមិន បេះរត់ទៅណាទេ ។

ដានី ៖ ចុះមេឃុំគេណែនាំថាម៉េច?

យ៉ន ៖ គេណែនាំថា «មិនខុសទេ បងអើយបង គេថាអគ្គការបញ្ជាបងឯងទៅពាយ័ព្យ អត់មានកម្លាំងកម្មាភិបាល ព្រោះកម្លាំងបញ្ជូនមកយើងនេះច្រើនណាស់ ។ ចឹងទៅខាងនោះខ្វះកម្មាភិបាល» ។ គេបញ្ជូនមក ម៉ានិរតី ។

ដានី ៖ កាលហ្នឹងមេឃុំៗឈ្មោះអី មេឃុំដែលប្រាប់ឈ្មោះអីហ្នឹង?

យ៉ន ៖ មេឃុំហ្នឹងឈ្មោះគាត់ នួន ជូ ។

ដានី ៖ នួន ជូ?

យ៉ន ៖ បាទ!

ដានី ៖ សព្វថ្ងៃគាត់នៅរស់អត់?

យ៉ន ៖ ស្លាប់អស់ហើយ ថាក្បត់ ចាប់មួយៗថាក្បត់ សុទ្ធតែថាក្បត់ទាំងអស់ ដល់បញ្ជូនខ្ញុំមកគាត់នៅ ។

ដានី ៖ ចឹងគេបញ្ជូនមក ដូចថាឲ្យគេអីធ្វើដំណើរយ៉ាងម៉េច ហើយខាងលើគេមានណែនាំថា អីមកពាយ័ព្យ អីត្រូវអនុវត្តការងារ ត្រូវគ្រប់គ្រងប្រជាជនយ៉ាងម៉េចៗ គេមានប្រាប់ថាម៉េច?

យ៉ន : ចាំមើលខ្ញុំនិយាយស្ដាប់ឲ្យបានទាំងអស់ មកបញ្ជូនខ្ញុំមកចូលមកតាកែវសិននៅវិទ្យាល័យតាកែវៗកន្លះខែ បានបើកវគ្គ ។ តាម៉ុកបានបើកវគ្គរៀនសូត្រកម្មាភិបាលហ្នឹង គាត់ក្ដាប់ទិសដៅ ។

ដានី : បាទ! បើកវគ្គរៀនសូត្រយ៉ាងម៉េច?

យ៉ន : បើកវគ្គរៀនសូត្រឲ្យគួនាទីសមមិត្តទាំងអស់នេះសុទ្ធជាកម្មាភិបាល ព្រោះនៅខាងសុទ្ធភូមិភាគពាយ័ព្យកម្មាភិបាល ភាគច្រើនល្អ ខ្លះមិនល្អទេ ។ ដូច្នេះយើងត្រូវបញ្ជូនកម្មាភិបាលទៅធ្វើការងារនៅទីនោះ ។ ចឹងត្រូវចេះស្ដាប់អំពីសភាពការណ៍ខ្មាំង ។ ខ្មាំងមានសកម្មភាពច្រើនណាស់ បំភ្លេចបំផ្លាញរបស់រូម ។

ដានី : បាទ! ម៉េចទៀតទៅ?

យ៉ន : ហ្នឹងការងារតែប៉ុននឹង ។

ដានី : បាទ! គាត់បើកវគ្គ គាត់ប្រជុំប្រាប់ដូចថាអី ដូចថាកម្មាភិបាលទាំងអស់ត្រូវមានតួនាទីត្រូវមកជួយនៅភូមិភាគពាយ័ព្យ?

យ៉ន : បាទ!

ដានី : ដូចថានៅភូមិភាគពាយ័ព្យនឹង មានកម្មាភិបាលខ្លះអាក្រក់ កម្មាភិបាលខ្លះល្អ យើងបានធ្វើការ?

យ៉ន : ធ្វើជាមួយគ្នាហ្នឹង ។

ដានី : ធ្វើជាមួយគ្នា ប៉ុនយើងតាមដានគេ?

យ៉ន : តាមដានគេ មើលសកម្មភាពគេ យើងមកដល់ យើងមិនមែននៅលើគេទេ គេនៅពីលើយើង ។

ដានី : ប្រជុំជាមួយតាម៉ុកនៅតាកែវនឹងរយៈពេលប៉ុន្មាន?

យ៉ន : រយៈពេល អ៊ើ!ដូចកន្លះខែហើយលោកក្មួយ ។

ដានី : កន្លះខែគាត់មកប្រជុំរាល់ថ្ងៃ?

យ៉ន : បាទ! ប្រជុំមានពេលខ្លះកម្មាភិបាលផ្សេង គាត់មកពេល ។

ដានី : ពីណាខ្លះក្រៅពីតាម៉ុក មានពីណាទៀត?

យ៉ន : ដល់ហ្នឹងមានតាម៉ុក ។

ដានី : តាម៉ុកមួយទេ?

យ៉ន : បាទ! ក្រៅពីហ្នឹងមានគណៈតំបន់គណៈអីគេ ។

ដានី ៖ គណៈតំបន់ឈ្មោះអីគេ?

យ៉ន ៖ គណៈតំបន់ខាងហ្នឹង ខ្ញុំភ្លេចឈ្មោះដែរហើយ ។

ដានី ៖ គាទិតអីដែរ?

យ៉ន ៖ គាទិតគាត់មកជាមួយខ្ញុំដែរ ។

ដានី ៖ គាទិតមកជាមួយដែរ?

យ៉ន ៖ បាទ! ជួបគ្នាបាត់ដំបង ជួបគាទិត ។

ដានី ៖ អូ! ជួបគាទិតនៅបាត់ដំបង?

យ៉ន ៖ បាទ! គាទិតមកនេះតំបន់ ។

ដានី ៖ គាទិតគាត់ឋានៈអីគេ?

យ៉ន ៖ មកនៅបាត់ដំបងយើងនេះ គាត់គណៈតំបន់ ។

ដានី ៖ គណៈតំបន់ប៉ុន្មាន?

យ៉ន ៖ បាទ!

ដានី ៖ គណៈតំបន់ប៉ុន្មាន?

យ៉ន ៖ កាលហ្នឹងតំបន់ប៉ុន្មានទេ ខ្ញុំរត់ទៅគាត់អ្នកស្គាល់ភូមិសាស្ត្រច្បាស់ណាស់ ឈប់ទៅទៀតទៅត្រឹមកំពង់ឆ្នាំង ស្គាល់ភូមិសាស្ត្រច្បាស់ ។

ដានី ៖ អូ! គាទិតត្រូវជាម៉េចតាម៉ុក?

យ៉ន ៖ មិនដឹងត្រូវជាម៉េច បែបហ្នឹងមកបានស្គាល់គាត់ទៅប្រជុំទៅជួបគ្នា ។

ដានី ៖ ប្រជុំនៅតាកែវហ្នឹង?

យ៉ន ៖ បាទ! ប្រជុំនៅយើងបាត់ដំបងនេះ ដល់មកទៅក៏ជួបគាត់ហ្នឹង ។

ដានី ៖ ប៉ុន្តែកាលនៅតាកែវអត់ទេ?

យ៉ន ៖ អត់ ។

ដានី ៖ កាលមុនគាត់ខ្លះ គាត់តួនាទីធ្វើអី?

យ៉ន ៖ គាទិតមកមុនដំបូងឋានៈចៅហ្វាយស្រុក មកដល់នេះឡើងតំបន់ ។

ដានី ៖ តំបន់ៗនៅពាយ័ព្យមានតំបន់១ តំបន់២ តំបន់៣?

យ៉ន ៖ តំបន់បើយើងឥឡូវចៅហ្វាយខេត្ត ។

ដានី ៖ កាលពីភូមិភាគពាយ័ព្យវាមានតំបន់ច្រើន?

យ៉ន ៖ បាទ! តំបន់ច្រើនដូចនៅក្នុងតំបន់៤ ។

ដានី ៖ តាទិតនៅតំបន់៤?

យ៉ន ៖ បាទ! អី!តាទិតដូចនៅតំបន់៣ ។

ដានី ៖ គាត់មិនមែនគណៈភូមិភាគទេ?

យ៉ន ៖ មិនមែនភូមិភាគទេ ។

ដានី ៖ កាលហ្នឹងគណៈភូមិភាគពីណាគេ?

យ៉ន ៖ គណៈភូមិភាគតា រស់ ញឹម ។

ដានី ៖ តែផុតក្រៅពីតាញឹមទៅ?

យ៉ន ៖ តាញឹម តាម៉ុកដាក់មក ឈ្មោះ អ៊ំសៀន ។

ដានី ៖ ឈ្មោះអីគេ?

យ៉ន ៖ អ៊ំសៀន ។

ដានី ៖ អ៊ំសៀននៅណាទៅ?

យ៉ន ៖ អ៊ំសៀនហ្នឹងគាត់ធំរបស់គាត់ដែរ ដៃផ្ទាល់របស់តាម៉ុក ។

ដានី ៖ ដៃផ្ទាល់ឈ្មោះ សៀន?

យ៉ន ៖ បាទ! អ៊ំសៀន ។ របាយការណ៍ខ្ញុំ បើអត់ដល់តា មកដល់ជាមួយបងសៀនតាមដានសភាពការណ៍ ។

ដានី ៖ បើមុនរបាយការណ៍មិនផ្ញើទៅតាសៀនទេ ផ្ញើទៅតាម៉ុកផ្ទាល់?

យ៉ន ៖ បាទ! តែតាម៉ុកថានៅហ្នឹងមានសមមិត្តសៀននៅហ្នឹងហើយកុំភ័យ តែបើធ្វើការត្រង់ បើធ្វើការមិនត្រង់តាមដំណើរ ។

ដានី ៖ អ៊ំស្គាល់តាទិតច្បាស់ម៉ង?

យ៉ន ៖ តាទិតខ្ញុំស្គាល់ ។

ដានី ៖ អត់មានរាប់អានគាត់ជិតស្និតអត់?

យ៉ន ៖ អត់បានរាប់អានផងលោកក្មួយ បើបានមកប្រជុំគឺជួប អានឹងគឺប្រកាសអំពីសមាសភាពកម្មាភិបាល គេបង្ហាញងើបឈរៗមើល ។

ដានី ៖ មានពីណាខ្លះ ក្នុងគណៈតំបន់ពាយ័ព្យហ្នឹង សមមិត្តសៀន ក្រៅពីមិត្តសៀន មានពីណាទៀត ដែលគាត់?

យ៉ន ៖ អូ! ធំមានតែ២ហ្នឹង ។

ដានី ៖ ពីណាខ្លះ?

យ៉ន ៖ មានក្រោមការគ្រប់គ្រង តាញីមៗ គាត់អត់នៅហ្នឹង បន្ទាប់មកបងសៀន ។

ដានី ៖ ចុះតាកឹ តា?

យ៉ន ៖ អូ! នឹងជិនាន់មុន សុទ្ធតែគណៈតំបន់ ។

ដានី ៖ តាហេងទាវអី តាកែវ?

យ៉ន ៖ ជិនាន់តាទាវ ខ្ញុំតារស់ ញីមមកដល់នេះ នោះមិត្តតាទំពែងនោះអាហ្នឹងអន្តរវង្សខ្ញុំ ។

ដានី ៖ ពីណាគេ?

យ៉ន ៖ តាហៀងៗ ។

ដានី ៖ ចុះកាលអ៊ំរៀននៅតាកែវ កន្លះខែចឹងរៀនទាក់ទងពីៗមកធ្វើការជាមួយ ។

យ៉ន ៖ អឺ! រឿងសភាពការណ៍ ។

ដានី ៖ សភាពការណ៍?

យ៉ន ៖ រឿងសភាពការណ៍ ឲ្យយើងចេះ ។

ដានី ៖ ចឹងដល់ពេលហ្នឹង បន្ទាប់ពីរៀនៗហ្នឹងនៅកន្លែងណា?

យ៉ន ៖ នៅសាលាអនុវិទ្យាល័យ ឬវិទ្យាល័យទេ អូ!អាហ្នឹងមានឡូគេធ្វើក្បៀងហ្នឹងមួយទៀតទៅ ហួសតិចទៅ វិទ្យាល័យ អនុវិទ្យាល័យ ។

ដានី ៖ បាទ! ផ្ទះតាម៉ុកគាត់នៅក្នុងបឹងមួយ កន្លែងជិតដូនកែវ?

យ៉ន ៖ ផ្ទះគាត់ក៏នៅក្បែរហ្នឹងដែរ តានោះ ដែលខ្ញុំដឹងថាកន្លែងនោះ កន្លែងឡូក្បឿងឡូអី បាទ! ហើយយើងដើរតែបន្តិចទៅទល់សាលារៀន ។

ដានី ៖ ចុះប្រពន្ធអ៊ំគាត់ចូលរៀនដែរ?

យ៉ន ៖ ទៅ រៀនទាំងអស់គ្នា ។

ដានី ៖ រៀនទាំងអស់គ្នា?

យ៉ន ៖ មីងៗ បាទ!ចុះម៉ារទេះភ្លើងហ្នឹង មិនតិចរាប់រយនាក់ ទាំងទ័ពជង ទាំងអីជងបុកពេញគ្នា កងនារីៗ ម៉ាខ្សែៗរទេះភ្លើង ។

ដានី ៖ តាម៉ុកគាត់ទៅរៀន?

យ៉ន ៖ បាទ! ទាំងអស់ទៅពេញ ។

ដានី ៖ ខែ៦ ឆ្នាំ៧០?

យ៉ន ៖ ៧៧ ។

ដានី ៖ ខែ៦ ឆ្នាំ៧៧ ។ ចឹងដល់ពេលរៀនចប់យ៉ាងម៉េចទៅ រៀនចប់ពីតាកែវ?

យ៉ន ៖ រៀនចប់មក បានប្រាប់ទិសដៅមកហើយ អាខ្លះធ្លាក់សៀមរាបអីទៅដល់ណាឲ្យតែឆ្ពោះទៅ នោះគឺថាពាយ័ព្យ ។ ខ្លះធ្លាក់ទៅសៀមរាប ខ្លះទៅដល់កំពង់ធំអីនោះ ។

ដានី ៖ ចុះអ៊ំៗធ្លាក់មកដល់ណា?

យ៉ន ៖ ខ្ញុំៗមកដល់ត្រឹមបាត់ដំបង ។

ដានី ៖ ត្រឹមបាត់ដំបង?

យ៉ន ៖ បាទ!

ដានី ៖ អ៊ំនៅណា?

យ៉ន ៖ ខ្ញុំនៅដូនទាវ ស្រុកដូនទាវ ។

ដានី ៖ នៅគុល ដូនទាវ?

យ៉ន ៖ បាទ! នៅភូមិគុលហ្នឹង ។

ដានី ៖ មកដល់ហ្នឹងអ៊ំទទួលអីគេ?

យ៉ន ៖ ទៅហ្នឹងខ្ញុំកងផលិតធំម្តង ។

ដានី ៖ បាទ?

យ៉ន ៖ ដូចមេឃុំដែរហ្នឹង ។

ដានី ៖ គេហៅមេឃុំ?

យ៉ន ៖ បាទ! គេអត់ហៅមេឃុំទេ ។

ដានី ៖ គេហៅអីគេ?

យ៉ន ៖ កងផលិតធំ ។

ដានី ៖ កងផលិតធំ?

យ៉ន ៖ បាទ! យើងមានច្រើនដែរ ៥០០-៦០០នាក់ ។

ដានី ៖ ៥០០-៦០០នាក់?

យ៉ន ៖ បាទ! ម៉ាសហករណ៍ ។

ដានី ៖ អាហ្នឹងសហករណ៍ធំ?

យ៉ន ៖ បាទ! វាមិនចំឈ្មោះថាហៅសហករណ៍ កងផលិតធំ ។

ដានី ៖ គេហៅកងផលិតធំ?

យ៉ន ៖ បាទ! កងផលិតធំ ។

ដានី : ក្នុងស្រុកអីគេអាហ្នឹង?

យ៉ន : អាហ្នឹងនៅក្នុងស្រុកដូនទាវ ។

ដានី : ស្រុកដូនទាវ?

យ៉ន : ភូមិក្ដុល ។

ដានី : ក្នុងស្រុកដូនទាវក្នុងតំបន់អីគេអាហ្នឹង?

យ៉ន : ហ្នឹងតំបន់៤ ។

ដានី : កាលហ្នឹងតាទិត គាត់មិនមែនគណៈតំបន់៤ហ្នឹងទេ?

យ៉ន : បាទ! មិនមែនទេ មកគណៈតំបន់ហ្នឹង តាម៉ុកចាត់តាំងមកមនុស្សខូចខិលឈ្មោះ ឯក ។

ដានី : ឈ្មោះឯក?

យ៉ន : បាទ! មកពីខាងតាកែវ ។

ដានី : ខូចខិលម៉េចទៅ?

យ៉ន : អឺ! មកនេះវាផ្ដេសផ្ដាសសម្លាប់ទាំងខ្ញុំ ទាំងគេ គាត់ខិលតែរឿងសីលធម៌ ។

ដានី : អូ! គាត់ចូលចិត្តស្រីញី?

យ៉ន : បាទ! បានទ្រីស្ដីឪម៉ែប៉ុន្មាន ឡើងមកឲ្យធ្វើធំទៀត នារីៗនៅកងចល័តស្រេចតែគាត់វ៉ាស់ទាំងអស់ ។

ដានី : អ៊ឹអត់ចូលចិត្តគាត់ទេ?

យ៉ន : បាទ?

ដានី : អត់ចូលចិត្តគាត់?

យ៉ន : អូ! ទម្រាំតែតាម៉ុកដឹងដកយកទៅក្រោយវិញ បែបសម្លាប់បាត់ក៏មិនដឹង ។

ដានី : ដកយកទៅវិញដែរ?

យ៉ន : បាទ! ដកយកទៅវិញ ខូចគេខូចឯងអស់ខាងនេះគេយកវ៉ៃយើងចោល គេពីនោះមកគ្មានអាណាមួយល្អសោះ ។

ដានី : គេមកដែរ?

យ៉ន : ហើយពួកគេអ្នកល្អៗដែរ ។ ហើយយើងមកចឹង ហើយបើនិយាយពូកែខាងទ្រឹស្ដីទៀត វ៉ាអនុវត្តមកខូចអស់ដូចមកបំភ្លៃចឹង ។ តាគាត់ហាមពីនោះមកដែរ ថាពួកឯងយ៉ាប់ទាំងអស់ស្រីៗស្អាតៗណាស់ ។ ដល់អាណាខុសសីលធម៌មិនបាច់យកមកវិញ មកវិញដាក់ចានតែម៉ង ។

ដានី ៖ គាត់ថាចឹង?

យ៉ន ៖ បាទ! មកវិញដាក់ចាន អត់យកឯងមកវិញ ។

ដានី ៖ ឈ្មោះ ឯក?

យ៉ន ៖ បាទ! ឯក ។

ដានី ៖ ឯកហ្នឹងនៅស្រុកណា?

យ៉ន ៖ នៅតាកែវលោកក្មួយ ដឹងនៅភូមិលាយបូមិនដឹង ជំនាន់ហ្នឹងជួបគ្នាច្រើនណាស់ មកស្គាល់គ្នាវហូត ។

ដានី ៖ តែម្នាក់ហ្នឹង?

យ៉ន ៖ បាទ! តែម្នាក់ហ្នឹងនាំអាតគ្នារួមខូចអស់ ។

ដានី ៖ បាទ! ប៉ុន្តែគណៈតំបន់៤មកពីតាកែវតែម្នាក់ហ្នឹង?

យ៉ន ៖ តែម្នាក់ហ្នឹង ។

ដានី ៖ ចុះគណៈស្រុកដូនទាវ?

យ៉ន ៖ គណៈស្រុកដូនទាវក៏មកពីយើងដែរ មកដល់រៀបចំសុទ្ធតែតាកែវដែរ ។

ដានី ៖ ឈ្មោះអីគេ?

យ៉ន ៖ មកតាអេនៗ យើងនៅនេះ ។

ដានី ៖ ណាគាត់នៅណា?

យ៉ន ៖ ឥឡូវហ្នឹងគាត់ឈរនៅនេះបវេលនេះ ជំនាន់ហ្នឹងវីសៗហ្នឹងស្លាប់ៗដែរ ។

ដានី ៖ តែឥឡូវគាត់នៅរស់ដែរ?

យ៉ន ៖ បាទ! គាត់នៅរស់ ។

ដានី ៖ គាត់នៅណាទៅឥឡូវ?

យ៉ន ៖ នេះអត់ដែលបានជួបគ្នា នៅយើងម្តុំយើង មិនដល់កាប៊ីនទេ ត្រឹមអូរអន្ទក់នេះ កាលហ្នឹងខ្ញុំឥឡូវមិនដែលបានធ្វើការជួបគ្នា ។

ដានី ៖ នៅម្តុំអូរអន្ទក់?

យ៉ន ៖ បាទ!

ដានី ៖ ប្រពន្ធគាត់ឈ្មោះអីគេ?

យ៉ន ៖ ប្រពន្ធអូរភ្លេចបាត់ហើយលោកក្មួយ ភ្លេចឈ្មោះប្រពន្ធគេអស់ ។

ដានី ៖ ខ្ញុំចង់ជួបគាត់ដែរ ។

យ៉ន ៖ អេន ។

ដានី ៖ សួរគេៗ ឥឡូវគាត់ឈ្មោះ តាអេន ដដែល?

យ៉ន ៖ អាហ្នឹងដឹងថាស់ឈ្មោះ តែអត់ផ្លាស់ទេ តាហ្នឹង មនុស្សកងទ័ព ។ ខ្ញុំនៅជាមួយគាត់ហ្នឹង ។

ដានី ៖ គាត់គ្រប់គ្រងស្រុក អីគ្រប់គ្រង?

យ៉ន ៖ បាទ! ឃុំ យើងកងព្រលិត ។

ដានី ៖ កងព្រលិតនៅ?

យ៉ន ៖ ខ្ញុំនៅភូមិក្តុលពីដើម ។

ដានី ៖ ភូមិក្តុល?

យ៉ន ៖ ភូមិក្តុល ឃុំក្តុល ។

ដានី ៖ តាអេន គាត់អត់អីទេ បរិបូរទេ?

យ៉ន ៖ អត់អីទេ គាត់មុឺនម៉ាត់ តែអាអ្នកលំដាប់ក្រោមនោះទៅវៃមនុស្សចោល បានសម្រេចចិត្ត ខ្លួនឯង ខាងលើជាត់កំពីសដឹងថាសាប់ ។

ដានី ៖ ខាងណា ខាងក្រោមណាសម្រេចចិត្ត?

យ៉ន ៖ ខាងក្រោមនេះ ប្រហែលជាកងផលិតនិងមេឃុំហ្នឹង ដែលវាវៃ ។

ដានី ៖ អូ! ថ្នាក់ប្រហែលៗអីហ្នឹង?

យ៉ន ៖ បាទ! វៃមនុស្សចោល ។

ដានី ៖ វៃច្រើន?

យ៉ន ៖ បែបជ្រុលដៃតែម្នាក់ទេតាមមើលទៅ ដល់ចឹងទៅវាកុនតែចៅហ្វាយស្រុកនេះ ។

ដានី ៖ កុនតាអេននេះ?

យ៉ន ៖ បាទ! វេសតែខាងលើយកទៅវៃចោល ។

ដានី ៖ ចុះតាទិត?

យ៉ន ៖ ចុះកាលហ្នឹងគេហាមដាច់ខាតមិនឲ្យប៉ះពាល់ ។

ដានី ៖ ចុះកាលនោះតំបន់៤ នៅកន្លែងណាទៅ កន្លែងតំបន់?

យ៉ន ៖ បាទ! តំបន់៤មិនមែនជាកន្លែងមន្ទីរណាទេ ព្រោះថាបើពីត្រឹមខ្ញុំហ្នឹងវាតំបន់៤ ស្រុកដូនទាវវានៅក្នុងតំបន់៤ ។ ហើយបើមិនដឹងវាមានប៉ុន្មានស្រុកទៀត ។

ដានី ៖ តែមន្ទីរតំបន់មិនដឹងនៅណា?

យ៉ន ៖ បាទ! មិនដឹងនៅណា ។

ដានី ៖ អ៊ំស្គាល់តែឈ្មោះឯក?

យ៉ន ៖ ហ៎! តែបើតាឯកមកហ្នឹង ប្រជុំហ្នឹង ប្រជុំនៅវត្តដូវដូនទាវហ្នឹងតែម្ដង ហ្នឹងតំបន់ហ្នឹងទៅហើយ ។

ដានី ៖ អូ! ដល់ពេលតាឯកមកនឹង តំបន់នៅហ្នឹង?

យ៉ន ៖ បាទ! ចុះគេឡើងតំបន់ហ្នឹង ហៅស្រុកគ្រប់ស្រុកមកប្រជុំហ្នឹង ។

ដានី ៖ បាទ! ប៉ុនផ្ទះគាត់នៅហ្នឹងដែរ?

យ៉ន ៖ បាទ! ផ្ទះនៅហ្នឹងវត្តគុលហើយ ។

ដានី ៖ ចុះតាទិតនៅណាទៅ?

យ៉ន ៖ ខ្ញុំនៅស្រុកកំណើតតាទិតខ្ញុំអត់ច្បាស់ បានតែស្គាល់ហ្នឹង ។

ដានី ៖ បាទ! ប៉ុន្តែតាទិតគាត់មកៗនៅគណៈតំបន់៣?

យ៉ន ៖ តាទិតគាត់ដូចតំបន់៣ចឹងហើយតាទិត ។ តំបន់៤ តំបន់៥ ។

ដានី ៖ តាឯក តំបន់?

យ៉ន ៖ បាទ! តំបន់៤ តាឯក ។

ដានី ៖ ស្គាល់គាត់ច្បាស់ធ្លាប់និយាយលេងជាមួយគាត់ដែរ?

យ៉ន ៖ ធ្លាប់លេងជាមួយគ្នា ។

ដានី ៖ គាត់នៅណាទៅឥឡូវ?

យ៉ន ៖ បែកគ្នាកាលហ្នឹងរត់ម៉ារ៉ាវហ្នឹង ខ្ញុំធ្លាក់ដល់លាច ទៅតាទិតគាត់ស្គាល់ផ្លូវ គាត់ថាទៅភ្នំទិរ៉ាល់ម៉ឺនទៅ កន្លែងតស៊ូ បានរស់ មានស៊ីតាម៉ុកនៅលាចដែរ ។ ឲ្យនារសាមក ដេញរត់មកវិញ "ឯងរត់ទៅឯរាប់យកណា ពីនោះរត់មកដល់នេះតាមផ្លូវជាតិលេខ៤ ឯងរត់ទៅរកទៅណាវិញ ទៅរកអត់អីស៊ី" ។

ដានី ៖ តាម៉ុកទៅហៅតាទិត?

យ៉ន ៖ បាទ! តាម៉ុកឲ្យបកទៅវិញ គាត់ថា"បញ្ជូនអាមួយមកបាត់ៗពួកនេះវៃចោលទាំងអស់អត់ចេះស្ដាប់អាណាសោះ ឯងបញ្ជា" ទាល់តែគាត់ឡើងលើឡានគាត់ ខ្វែងដៃខ្វែងជើងឲ្យត្រឡប់មកវិញទាំងអស់ មកបង្វែរនេះបានរស់ ស្រូវនៅនេះឯងទៅនោះគ្មានស៊ីស៊ីយួនស៊ី ខ្ទេច ។

ដានី ៖ កន្លែងតាទិតនៅបាត់ដំបង នៅម្ដុំណា កាលគាត់អ៊ំនៅដូនទាវ?

យ៉ន ៖ ខ្ញុំនៅដូនទាវ ។

ដានី ៖ តាទិតគាត់នៅ?

យ៉ន ៖ គាត់ដឹងកន្លែងគាត់កន្លែងនៅណាទេ ។

ដានី ៖ តែពេលដែលប្រជុំបានជួបគ្នា?

យ៉ន ៖ បាទ!

ដានី ៖ ទៅប្រជុំនៅណាបានជួបគ្នា?

យ៉ន ៖ ប្រជុំមកចឹង មានតែមកកន្លែងតារស់ ញឹម ។

ដានី ៖ កន្លែងតារស់ ញឹមនៅម្តុំណា?

យ៉ន ៖ កន្លែងតារស់ ញឹម ហ្នឹងនៅយើងនៅអន្លង់វិល ។

ដានី ៖ អន្លង់វិល កន្លែងអីគេ គេហៅអី?

យ៉ន ៖ នៅជិតព្រលានយន្តហោះ ។

ដានី ៖ នៅជិតវាលបែកចាន?

យ៉ន ៖ បាទ! វាលបែកចាន ។

ដានី ៖ កន្លែងសាលាសកលហ្នឹង?

យ៉ន ៖ កន្លែងហ្នឹងកន្លែង ឥឡូវបែបសាលាពីដើម តាមមើល... ។

ដានី ៖ ខស្សាហ៍ប្រជុំដែរចឹង?

យ៉ន ៖ បាទ! ទៅប្រជុំតែហ្នឹង ថ្នាក់កម្មាភិបាលអាហ្នឹងតាញឹមគាត់អ្នកប្រជុំ ។

ដានី ៖ តាម៉ុកដែរ?

យ៉ន ៖ តាម៉ុកនៅយូរៗ គាត់បាន គាត់មិនសូវបានមកទេ នៅនេះបានអាងតាញឹម តាសៀន គាត់ដឹងថារួម ។

ដានី ៖ តាញឹម តាសៀន ហើយគណៈតំបន់មានតាទិត តាឯក ហើយគេដកតាឯកទៅគេមានដាក់ ពីណាផ្សេងទៀតមក?

យ៉ន ៖ ជិនាន់នឹង ពេលវេលាចង់ភិតជាយហើយអស់ ចាប់ៗនោះចាប់អស់ហើយ តាំងពីតាញឹម អីនោះ ចាប់រហូត ។

ដានី ៖ តាសៀន អត់ទេ តាសៀន គាត់នៅហ្នឹងរហូត?

យ៉ន ៖ បាទ! គាត់នៅរហូត ។

ដានី ៖ សៀន គាត់នៅណាឥឡូវ?

យ៉ន ៖ មិនដឹងជានៅ ។

ដានី ៖ បាទ?

យ៉ន ៖ មិនដឹងជានៅណា ។

ដានី ៖ តែគាត់នៅរស់ទេ?

យ៉ន ៖ ហ៎! កាលហ្នឹងគាត់ចាស់ដែរ មិនដឹងយ៉ាងម៉េច ដកទៅជំនាន់ដកតាញ៉ឹមទៅមិនដឹង លែងដឹងហើយ យើងជិត១៧៩ហើយ យើងប្រឹងកាលនោះ...បែកគ្នាអស់ ។

ដានី ៖ ចុះក្រៅពីតាឯក តាទិត ពីណាខ្លះទៀត ដែលមកក្នុងគណៈតំបន់ វាមានគណៈតំបន់១ គណៈតំបន់២ ៣?

យ៉ន ៖ ខ្ញុំអត់សូវស្គាល់ក្មួយ ច្រើនណាស់គណៈតំបន់ វាតំបន់៣ តំបន់៤ តំបន់៥ មិនសូវបានជួបគ្នា ។

ដានី ៖ ចុះយាយថែម?

យ៉ន ៖ បាទ?

ដានី ៖ ស្គាល់យាយថែម?

យ៉ន ៖ ខ្ញុំអត់ស្គាល់ទេលោកក្មួយ ។

ដានី ៖ យាយថែមគាត់មកនៅខាងព្រះនេត្រព្រះតំបន់៥ ។ គណៈតំបន់៥ពីណាគេ?

យ៉ន ៖ មាន មិនសូវបានស្គាល់ ។

ដានី ៖ ចឹងមកអ៊ីវិញ ខ្ញុំចង់ដឹងពីការងារអ៊ី ដល់ពេលអ៊ីមកធ្វើខាងអ៊ីវិញ មកកាន់ក្តាប់ខាងកងផលិតធំហ្នឹង យើងការងារយ៉ាងម៉េចខ្លះទៅ?

យ៉ន ៖ ការងារលោកក្មួយអើយ បែងចែកតែពីរឿងធ្វើស្រែ ម៉ាហិចតាដាក់បទបញ្ជា៣តោន១ឲ្យបាន ។

ដានី ៖ ពីណាគេអ្នកដាក់បទបញ្ជា?

យ៉ន ៖ បាទ?

ដានី ៖ ពីណាដាក់បទបញ្ជា?

យ៉ន ៖ បទបញ្ជាហ្នឹង អី!ពីថ្នាក់លើមកតំបន់ គឺ៣តោនសកជាប្រចាំចឹងម៉ង ។

ដានី ៖ ថ្នាក់លើណា៣តោន តាម៉ុក?

យ៉ន ៖ តាម៉ុក មានណាទេជំនាន់នោះមានតែតាម៉ុក ៣តោន១ គឺចាំ៣តោន ធ្វើបានមិនបាន គឺវិនិច្ឆ័យកម្មាភិបាលកម្លាំងប្រើប្រាស់គឺមាន ស្រេចតែលើយើងចាត់ចែងដីស្រែគេមានកម្លាំងមានធ្វើ អ្នកឯងធ្វើមិនបានជារឿងស្លាប់របស់អ្នកឯង បោះប្រាវឡូច ។

ដានី :	ធ្វើបាប?

យ៉ន :	ធ្វើកាលហ្នឹងបានមែនលោកក្មួយមិនថាមិនបាន ខ្ញុំធ្វើតែស្រូវប្រាំងផង ខ្ញុំឈរធ្វើស្រូវប្រាំងអាងភាសន៍ខាងកើត ខ្ញុំធ្វើឡើង៥០០ហិចតា នៅឈរនឹងទាល់តែទម្លាក់គ្រាប់បែកយើងនៅលានបែកចាន ។

ដានី :	បាទ! ចុះអ៊ំដល់ពេល យើងដាក់ផែនការណ៍ធ្វើស្រូវ៣ហិចតាអី យើងធ្វើបានទេ?

យ៉ន :	បានលោកក្មួយ ។

ដានី :	បាន ហើយយើងបាន ស្រូវយកទៅណា?

យ៉ន :	វាយើងធ្វើបានហើយ ទាល់យួនវាមកចឹងទៅទាល់មិនទាន់រត់ប្រាស់អស់រលីងទៅថាមិនមែន៥០០ហិចតា គេឲ្យខ្ញុំធ្វើឲ្យហើយ កម្លាំងគេដាក់ពេញអស់ហើយ ។ ហើយយើងចាត់ចែងតាមកងទៅ វិធីប្រើប្រាស់គេបង្រៀនយើងអីទាំងអស់ភ្ជួរដី ។

ដានី :	កាលនោះគេបង្រៀនយើងពីដាក់ជីអី?

យ៉ន :	បាទ! បង្រៀនម៉ាចប់ ។

ដានី :	ហើយចុះកម្លាំងផលិត ដល់ពេលនេះហ្នឹងប្រជាជនដែលថានេះហ្នឹងអត់ខ្វះទេ?

យ៉ន :	បាទ! អត់ខ្វះទេ កម្លាំងតាមកងគេនៅចាំធ្វើចឹង ទៅបោះដំរំបោះអី នៅសម្រាកធ្វើទាល់តែហើយបានយើងឡើង ។

ដានី :	ហើយចុះកាលហ្នឹងហូបចុះអីយ៉ាងម៉េចដែរ?

យ៉ន :	ហូបចុះ ហ៊ើកាលហ្នឹងដូចមិនសូវអីដែរទេ ព្រោះវាត្រង់នោះដូចខ្ញុំថាចឹងម្ហូបមិនបេះចប់ត្រីវិញថាសំបូរណាស់ វាកុញតែរឿងអង្ករតិចហ្នឹងម៊ង ថាម្ហូបអត់ទាស់ ។

ដានី :	ចុះប្រពន្ធអ៊ំគាត់ធ្វើអីទៅ?

យ៉ន :	អត់ផងគាត់មកដល់ហ្នឹងនៅតាមកងៗ គេឲ្យធ្វើចុងភៅ ខ្ញុំក៏មិនឲ្យមានភារកិច្ចធ្វើអីទេ ។

ដានី :	ចុះក្រែងគាត់កម្មាភិបាលដែល មានបានចូលរៀនជាមួយតាម៉ុកដែរ ម៉េចអត់ឲ្យធ្វើ?

យ៉ន :	បាទ! គេហៅទៅប្រជុំដែរ តែខ្ញុំមិនឲ្យធ្វើការងារឲ្យជួយការងារចុងភៅតាមកង៣០គ្រួសារ

ដានី :	ចុះអ៊ំមួយទៀតដែរ អ៊ំបានរៀនសូត្រជាមួយតាម៉ុកៗគាត់ថា ឲ្យយើងបេះតាមដានសកម្ម កម្មាភិបាលដូចថាកម្មាភិបាលល្អ ព្រោះយើងធ្វើរបាយការណ៍ៗ យកទៅឲ្យគាត់ ឬក៏ឲ្យអ៊ំសៀន?

យ៉ន ៈ យើងឲ្យអីសៀនក៏បាន បើការងាររនឹងបន្ត តែក៏ខ្ទង់ប្រហែលជាប៉ុន្មានខែក្រោយមកគាត់មក នៅបាត់ដំបងដដែលៗ ។

ដានី ៈ ពីណាគេ តាម៉ុក?

យ៉ន ៈ តាម៉ុកបាទ! គាត់មកនៅកន្លែងយើងវគ្គធំមូលជិតបែកចានដែរ ងាយស្រួលទាក់ទងបើថាមានការងារអីថា ។

ដានី ៈ ដល់ពេលគាត់មកនៅបាត់ដំបង តាញឹមម៉េចហើយ?

យ៉ន ៈ តាញឹមនៅហ្នឹងឡើយដែរ ។

ដានី ៈ នៅហ្នឹងឡើយដែរ?

យ៉ន ៈ បាទ! តាញឹមៗកាល៧៥ ៧៧ ៧៨ ចាប់ពីខ្ទង់៧៨ ។

ដានី ៈ ៧៨ ខែប៉ុន្មាន នៅបែកចាន?

យ៉ន ៈ អឺ! មិនដឹងខែភ្លេច ខ្ទង់ប្រហែល៧៨ហើយ ព្រោះ៧៩រត់ព្រេច ។

ដានី ៈ បាទ! ចុះអ៊ំខស្សព្រាហ៍រាយការណ៍សរសេររបាយការណ៍ឲ្យតាម៉ុក?

យ៉ន ៈ មិនសូវបានរាយការណ៍ប៉ុន្មានទេ លោកក្មួយ បើគាត់នេះម៉ង យើងរាយការណ៍មន្ទីរសភាពការណ៍ប្រជាជន ។ ហើយហ្នឹងវាមានយើងឲ្យចេះក្តាប់ថាវាខ្លាំងបំភ្លេចបំផ្លាញស្អី គ្នាវាអត់វាឃ្លាន អារឿងស៊ីចុកអីកុំចោទថាខ្លាំងដែរដូចវានឹកពេកចេះរាយ ខ្ញុំថាមិនរាយស្អី ។

ដានី ៈ គេរាយ?

យ៉ន ៈ អ្នកខ្លះកន្លែងខ្លះថារាយ?

ដានី ៈ តែអ៊ំអត់រាយទេ?

យ៉ន ៈ ខ្ញុំគ្រាន់បាត់គិចតួចចឹង មិនមានស្អីជាអស្ចារ្យ ខ្ញុំនឹកឃើញចឹងក៏ខ្ជិលរាយណាស់ ព្រោះគាត់គ្រាន់តែនិយាយថា វាធម្មតាដំឡូង ហើយមានចេកអីមុខផ្ទះចេះថាខ្លាំងៗអីគាត់ដាំគាត់ហូប ខ្ញុំនិយាយប្រដុំតាមកងនិយាយពេលខ្លះ ។

ដានី ៈ អ៊ំថាចឹង?

យ៉ន ៈ បាទ! ខ្ញុំប្រកាស ។

ដានី ៈ អត់ខ្លាចគេទីង អត់ខ្លាចកម្មាភិបាល?

យ៉ន ៈ អត់ទេ បើយើងគ្រប់គ្រងគេហើយ លែងខ្លាចហើយ ថា“ឥឡូវអ៊ំឯង លោកកូនអើយ លោកកូន ហៅ ចេកហ្នឹងម៉ាគុម្ពហ្នឹងដល់ឥឡូវវាចាស់” “ចុះបើចាស់ហើយទុំហូបទៅ” ។

ថា«អត់បានទេ ពីដើមយកវ៉ៃចោល»ថា«ខ្ញុំនេះហូបទៅ ដូងនេះមិនបាច់ប្រាប់អីទេ អាឆ្កាក់ មកទុំអីនេះ ហូបៗទៅ»ខ្ញុំថាចេះ ។

ដានី : ចុះកម្មាភិបាលចាស់ ដែលនៅជាមួយអ៊ីដូចគ្នា អ៊ីដែលមានរាយការណ៍ពីសកម្មភាពអីទៅ?

យ៉ន : មានតែគេរាយពីខ្ញុំ វាអាចរាយពីគេដែរ តែមើលទៅបើគេល្អនឹងយើងមានអី មានតែគេចាំរាយពីយើងដែរ ។

ដានី : គេរាយពីអ៊ីវិញ ។ ចុះដល់ពេលអ៊ីមកក្រោយមក នៅហ្នឹងកម្មាភិបាលភាគច្រើនគេចាប់ទៅ?

យ៉ន : កម្មាភិបាលនៅហ្នឹង?

ដានី : បាទ!

យ៉ន : គិតទៅមិនថាមកពីណាមកពីណែទេ បូព៌ាក៏ដោយ និរតីក៏ដោយ និយាយពីរឿងខុសៗពីទៅហើយអត់មានប្រកាន់ថាអ្នកឯងចេះចុះ អ្នកឯងនិរតី ថាខ្លាំងអីអត់មានទេ និយាយថាប្រព្រឹត្តខុស ទៅហើយ ។

ដានី : ស្លាប់ច្រើន កាលនោះគេចាប់ច្រើន?

យ៉ន : និរតីក៏ងាប់ វ៉ៃដូចគ្នា ដល់ធ្វើផែនការគេខូចចឹង នៅមិនបានមិនបាច់យល់ ។

ដានី : ពីណាគេអ្នកចាប់?

យ៉ន : ហឺ! តែគេចាប់សុទ្ធតែឡានមកលោកក្មួយ ។

ដានី : គេចាប់យកទៅណា?

យ៉ន : អត់ឃើញមេទេ ឃើញតែឡានមកឈប់ហៅមកទាំងប្ដីប្រពន្ធ រៀបចំទៅរៀនសូត្រទៅហើយ ។ ខ្ញុំគេឆ្លងប៉ុន្មានដងហើយ ត្រឹមអន្លង់វិល ។ ចឹងមកនេះមិនទាន់បានត្រៀមអីណាកំពុងអង្គុយលេង ហើយដល់ឡានមកដល់មុខផ្ទះបិទ អាហ្នឹងចុះអ្នកស្រុកគេថា "ចាប់ទៀតហើយៗ" "អឺ! ទៅបងឲ្យទៅរៀននៅអន្លង់វិល រៀបចំអីវ៉ាន់" ។

ដានី : ពីណាគេ?

យ៉ន : ពួកឡាន ។

ដានី : មកប្រាប់អ៊ំ?

យ៉ន : បាទ!

ដានី : ហើយម៉េចទៅចឹង?

យ៉ន ៖ ចុះអក្ខរក្សរបស់គាត់ហ្នឹងឲ្យមកប្រាប់ឲ្យទៅរៀន ។

ដានី ៖ របស់តាម៉ុក?

យ៉ន ៖ អក្ខរក្សតាញឹម ។

ដានី ៖ ហើយម៉េចទៅ?

យ៉ន ៖ ឲ្យទៅប្រជុំ ។

ដានី ៖ ទៅប្រជុំធម្មតាមែន?

យ៉ន ៖ បាទ! ទៅប្រជុំធម្មតា គ្រប់កន្លែងទាំងអស់រៀបចំប្រឹប ជាមួយគ្នានោះទៅ អ្នកនៅសហករណ៍នោះថាអូ!ចាប់អស់ទៀតហើយ ដើរភរគេភរឯង មកមិនទាន់ណាណៃផងចាប់ ។

ដានី ៖ ចុះអ៊ីកាលហ្នឹងខុសអី ដូចថាអ៊ីនិយាយដូចគេចាប់ច្រើនហ្នឹង ដូចខុសអីខ្លះទៅបានគេចាប់ទៅ?

យ៉ន ៖ អូ! អារឿងកម្មាភិបាល?

ដានី ៖ បាទ!

យ៉ន ៖ រឿងខុស តែរឿងយើងធ្វើឧទាហរណ៍ថា មិនសម្រេចផែនការណ៍គេ ឧទាហរណ៍ថាស្រូវធ្វើមិនបាន គេតាមដានយើងដែរ មិនបាន៣តោនបូកសរុបលទ្ធផលជារាយការ៍ចេះតែរាយៗប្រជាជនពលរដ្ឋអត់មានអីហូប រកស្រូវហូបមិនកប នៅតែបបរទេ អាហ្នឹងក្បត់ហើយមិនបាច់រកឆ្ងល់អីទេ អានោះត្រូវដកចេញរឹប ។

ដានី ៖ ក្បត់?

យ៉ន ៖ បាទ! ព្រោះយើងធ្វើអត់បាន ក្រែងលរមានគេអ្នកក្រោយខ្នងជាងយើងៗមិនដឹងទៅណាទេ ទៅហើយ ។ បើខ្ញុំធ្វើអត់បាន គឺខ្ញុំត្រូវថយហើយ ។

ដានី ៖ ចឹងអ៊ំធ្វើបាន?

យ៉ន ៖ ចឹងបានខ្ញុំថាធ្វើវិសតែបានហើយកដល់ពេល៧៩ មិនទាន់បានប្រមូលផលផង ។

ដានី ៖ ចុះដល់ពេលអ៊ំមកគ្រប់គ្រងប្រជាជនអីម៉េចដែរ គេមានបែងចែកអ្នកណាក្បត់ អ្នកណាមិនក្បត់ត្រូវចាប់ច្រើនដែរអត់?

យ៉ន ៖ អត់មានទេលោកក្មួយ យើងមានការអប់រំ កាលហ្នឹងយើងសម្រាលការចាប់ការចងអីអស់ហើយ ។

ដានី ៖ សម្រាលហើយនោះ?

យ៉ន ៖ សម្រាលអស់ហើយ ខៀវ សំផន ចេញប្រកាស ។

ដានី ៈ ខៀវ សំផនចេញប្រកាស?

យ៉ន ៈ បាទ!

ដានី ៈ ខៀវ សំផនចេញប្រកាសថាម៉េច?

យ៉ន ៈ កាលនោះប្រកាសតាមវិទ្យុផង ហើយនឹងឯកសារ ។

ដានី ៈ គាត់មានដែលចុះមកពាយ័ព្យ?

យ៉ន ៈ គាត់អត់ដែលមានចុះមកទេ ។

ដានី ៈ គាត់ប្រកាសនឹង ប្រកាសតាមវិទ្យុតាមអីទេ?

យ៉ន ៈ គាត់សម្រាលរដ្ឋអំណាច លែងមានប៉ះពាល់ឲ្យវើឲ្យអីដាច់ខាត ៧/៨ប្រកាសសម្រាលរដ្ឋអំណាច ។

ដានី ៈ ៧/៨ឆ្នាំណា ខែប៉ុន្មាន?

យ៉ន ៈ ចឹងបានវាគៀកៗនឹងអាដែល៧/៩ដែរហ្នឹងលោកក្មួយ នៅគៀកៗគ្នា ។

ដានី ៈ គៀកៗ?

យ៉ន ៈ គ្រាន់យើងសម្រួលតិចតួច ចាប់ផ្ដើមធ្វើមេទិញមេអីសន្និបាទហើយ សម្រាលរដ្ឋអំណាចហ្នឹងហើយ បានតែប៉ុន្មានខែ នេះតឹង ។

ដានី ៈ តាញឹមគេចាប់ហើយកាលហ្នឹង?

យ៉ន ៈ បាទ! ចាប់ហើយ ។

ដានី ៈ តាញឹមគេចាប់ អីដឹងមូលហេតុគេចាប់គាត់?

យ៉ន ៈ ខ្ញុំមិនសូវដឹងទេ ថ្នាក់ដឹកនាំ... ។

ដានី ៈ អីខស្សរាហ៍ប្រជុំជាមួយគាត់ដែរ តាមញឹមម៉េចដែរ មនុស្សគាត់?

យ៉ន ៈ ទេ! ខ្ញុំមើលសមត្ថភាពគាត់អ្នកចេះដឹងខ្លះ គាត់និយាយទៅស្ដាប់បាន និយាយគ្រួសារគាត់ទៀតសាស្ត្រាចារ្យទៀត ។ ខ្ញុំមើលអ្នកស្គាល់ យី!អ្នកដឹកនាំអ្នកធំដែលនិយាយទៅដូចជា ។

ដានី ៈ ចុះគាត់ហើយតាម៉ុកមើលទៅនិយាយដូចអត់ត្រូវគ្នា ឬយ៉ាងម៉េច?

យ៉ន ៈ អត់ទេ គាត់ហៅសមមិត្តម៉ុក ប្រាប់តែពួកខ្ញុំនេះ សមមិត្តម៉ុកឲ្យតែអ្នកណាខូចទៅវិញជិះចានហើយ ខំធ្វើការផាវ សមមិត្តម៉ុកថាម៉េចធ្វើចឹងហើយមិនដឹងទេ ។ ហើយខ្ញុំសួរគាត់មិនដឹងជាសម្រេចខាងណាចាប់ ។

ដានី ៈ តាទិត គ្រួសារគាត់ឈ្មោះអី?

យ៉ន ៈ ខ្ញុំមិនបានស្គាល់គ្រួសារទេ ។

ដានី :	តែគាត់ត្រូវសាច់ញាតិតាម៉ុកដែរ តាទិត?

យ៉ន :	មិនដឹងម៉េចសាច់ញាតិម៉េច ។

ដានី :	ប៉ុន្តែដឹងសាច់ញាតិ ត្រូវជាប់សាច់ឈាមតាម៉ុកដែរ?

យ៉ន :	ទេ!ដូចជាគាត់ខាងកំពង់ឆ្នាំង ព្រោះគាត់ស្គាល់ភូមិសាស្រ្តច្បាស់ ភ្នំឱរ៉ាល់អីច្បាស់ណាស់ ។

ដានី :	ចុះតាអាន?

យ៉ន :	បាទ?

ដានី :	តាអាន?

យ៉ន :	តាអាន?

ដានី :	បាទ!

យ៉ន :	ខ្ញុំអត់ស្គាល់ ។

ដានី :	អត់ស្គាល់តាអានទេ?

យ៉ន :	អត់ស្គាល់ មកនេះមានចាយមួយទៀត ។ តាចាយនោះអើយ! បូរាណសុទ្ធម៉ីង ។

ដានី :	តាចាយនោះនៅណា?

យ៉ន :	តាចាយនោះសុទ្ធតែជាមួយខ្សែតាម៉ុក ស្បែកជើងអត់បាច់ខ្សែអីច្រើនទៀតទេ គ្រាន់តែមេជើងមួយ អូ!.....សុទ្ធតែម៉ីងទៅ ។

ដានី :	គាត់ធ្វើអី តាចាយ?

យ៉ន :	គណៈតំបន់ដែរ ។

ដានី :	គណៈតំបន់ណា?

យ៉ន :	កាលនោះតំបន់គាត់ឈរនៅខាងណាទេ ។

ដានី :	នៅខាងពាយ័ព្យដែរ?

យ៉ន :	បាទ! មកហ្នឹងណា ។

ដានី :	មកពីតាកែវដែរ?

យ៉ន :	បាទ! វត់មកយើងបណ្តោយ យើងមកដល់នេះទៀត ចាយ ដែលស្លាប់បាត់ក៏មិនដឹងមកតាមផ្លូវរត់ព្រៃយើងហ្នឹង មកជាមួយគ្នាតាចាយ ។ មិនដឹងឡើងដល់ណាគាត់យូរខែដែរ តានេះអត់បាន ។

ដានី :	អូ! ទៅខាងអន្លង់វែងវិញ គាត់ទៅអន្លង់វែង តាចាយ គាត់នៅដែរ?

យ៉ន :	ចាស់ហើយ ។

ដានី ៖ គាត់ចាស់ហើយ?

យ៉ន ៖ បាទ!

ដានី ៖ ចុះពូស្គាល់តាអាន ។ គាត់នៅខាងអូរតាអា?

អ្នកជិតខាង ៖ ....អត់ស្គាល់អស់....។

ដានី ៖ ចុះអ៊ំកាលនឹងមួយទៀត អ៊ំកាលហ្នឹងធ្លាប់បានជួយគេឲ្យរស់អី ដូចថាគាត់ចាប់ ឬក៏គេប្រុង យកទៅសម្លាប់អីចឹង អ៊ំបានជួយគេឲ្យរស់អីដែរអត់?

យ៉ន ៖ ខ្ញុំបានជួយសង្គ្រោះបាន២នាក់ដែរ ។

ដានី ៖ អូ! បាន២នាក់ដែរ ។ យ៉ាងម៉េច?

យ៉ន ៖ មីមួយនោះគេបញ្ជូនវាមកនៅប៉ៃលិននេះ បើថាខ្ញុំដឹងដែនការ វារត់មកប្រាប់ខ្ញុំថា"បង អើយជួយខ្ញុំផង គេបញ្ជូនខ្ញុំទៅៗឲ្យទៅកាប់ឈើ"ថា"អើ!មិនមែនកាប់ឈើទេ គេបញ្ជូន ឯងឲ្យទៅឲ្យងាប់" "ទៅចាំអញជួយ" អាហ្នឹងវានៅស្រុកជាមួយខ្ញុំនោះ ។

ដានី ៖ គាត់ធ្វើអី?

យ៉ន ៖ គាត់ជាអ្នកឡើងត្នោត មករកស៊ីយើងនៅបាត់ដំបងហ្នឹង ហើយគាត់ធ្វើទាហាន ។

ដានី ៖ ធ្វើទាហាន?

យ៉ន ៖ បាទ! ធ្វើទាហានៗមកនេះទៅស្រាវជ្រាវថា"ចេះទាហាន" ទាហានទៅប្រាប់មេកង ប្រាប់ ខ្ញុំថា"មិត្តនេះឈ្មោះ ហៀប ធ្វើទាហាន" ស្មានទាហានស្អី ។

ដានី ៖ គាត់ឈ្មោះអីនឹងដែរ?

យ៉ន ៖ ឈ្មោះវា សៀនៗ ។

ដានី ៖ ឥឡូវនៅរស់ដែរអត់?

យ៉ន ៖ ស្លាប់បាត់ហើយ ។

ដានី ៖ ស្លាប់ពីអង្កាល់?

យ៉ន ៖ ស្លាប់ឆ្នាំទៅមិញ ។ ខ្ញុំទៅស្រុកទាំងប្រពន្ធទាំងអីលើកដៃ ។

ដានី ៖ នៅស្រុក អ៊ំនៅខាងកំពង់ស្ពឺនោះ?

យ៉ន ៖ បាទ!

ដានី ៖ ប្រពន្ធគាត់នៅទេ?

យ៉ន ៖ តែវាមានប្រពន្ធយើង ប្រពន្ធនៅខាងទន្លេជិតភ្នំពេញនេះ ទៅលេងស្រុកខ្ញុំទៅលេងស្រុក ជួបនេះ ទៅក៏គេថា"ខ្ញុំកុំបានលោកបងធ្វើការ គាត់ក៏បានជួយខ្ញុំឲ្យរួចពីសេចក្ដីស្លាប់" ។

ថ្ងៃមួយនៅបាត់ដំបងនេះរត់ទៅរកចង-ក ផាប់ ចង-កដើមអំពិលខ្ញុំថា វាក៏ឆ្លើយថា«មេនោះ ឈ្មោះមីយ៉ន១ ឡើងចង-កនោះ» ពួកឈ្លបគេមកប្រាប់ «វាមានរឿងអី» ។ គេថា«គេរកចាប់ទាហាន គាត់ភ័យ គាត់រត់ឡើងចង-ក» «ទៅហៅវាមក»

ដានី : គេចាប់អីគេ?

យ៉ន : សុទ្ធតែទាហាន វាភ័យខ្លួន ទៅក៏ខ្ញុំយកមកក៏«ឯងទៅចង-កធ្វើអី ចង-កផាប់បាត់ហើយ វាមិនអីទេ រឿងប៉ុននេះ អញដោះស្រាយរួចទេ វាគ្មានទៅផាប់ស្អីទេ អ្នកណាមកចាប់ អញឲ្យចាប់បានចាប់ គ្មានអ្នកណាមកចាប់រំលងទេអា៎»ថាចឹង ។

ដានី : ស្រី ប្រុស ស្រី?

យ៉ន : ប្រុស ។

ដានី : ប្រុស ឈ្មោះអី ឈ្មោះយ៉ន?

យ៉ន : ឈ្មោះយ៉ន ។

ដានី : សព្វថ្ងៃគាត់នៅរស់ទេ?

យ៉ន : បែបស្លាប់អស់ហើយ បែកគ្នាយូរហើយ ហ្នឹងនៅភូមិគុលហ្នឹងដែរ ។

ដានី : ស្រុកកំណើតភូមិគុលហ្នឹង?

យ៉ន : បាទ! ស្លាប់បាត់ហើយ ។

ដានី : ហើយឈ្មោះ សៀន ហ្នឹងគាត់ទើបស្លាប់ទេ?

យ៉ន : បាទ! ស្លាប់ប្រហែលឆ្នាំទៅមិញ ។

ដានី : ចុះប្រពន្ធនៅដែរអត់ ប្រពន្ធ?

យ៉ន : ប្រពន្ធ មិនដឹងដែរ ខ្ញុំខានទៅស្រុក ។

ដានី : ប្រពន្ធឈ្មោះអីនៅស្រុក?

យ៉ន : វាមិនស្គាល់ប្រពន្ធវាទៀត ។

ដានី : អូ! អីជួយបាន២នាក់ហ្នឹងដែរ?

យ៉ន : បាទ!

ដានី : ហ្នឹងសុទ្ធតែពាក់ព័ន្ធទាហាន?

យ៉ន : ពាក់ព័ន្ធទាហាន វាភ័យវា ។

ដានី : ទាហានលន់ នល់ ឆ្នាំណា?

យ៉ន : អាហ្នឹងឆ្នាំ៧/៨ដែរ ។

ដានី : ៧៨?

យ៉ន : បាទ!

ដានី : ឈ្មោះ សៀន ហ្នឹងត្រូវគេ គាត់រត់មកប្រាប់អ៊ំ មកប្រាប់ថាគេបញ្ជូនឲ្យទៅកាន់ឈើនៅប៉ៃលិន?

យ៉ន : បាទ! មកកាប់ឈើនៅប៉ៃលិននេះ ។

ដានី : ពីណាអ្នកប្រាប់ មេកង?

យ៉ន : មេកង ។

ដានី : គេប្រុងយកគាត់ទៅសម្លាប់?

យ៉ន : ឲ្យវាចងនៅហ្នឹង ដល់នេះវាមកផ្ទះខ្ញុំ រឿងហ្នឹងដឹងហើយ គេបញ្ជូនទៅហ្នឹងមិនដែលវិលវិញ ទេ ទៅបាត់រហូតៗហើយ ។

ដានី : អ៊ំជួយ បាន២នាក់ហ្នឹង?

យ៉ន : បាទ!

ដានី : ចុះអ៊ំនៅគុកលជូនទាវហ្នឹងរហូត នៅកងផលិតធំហ្នឹងរហូត អត់មានផ្លាស់ទៅណាទៀតទេ?

យ៉ន : បាទ! ខ្ញុំទើបតែរត់នៅ៧៩ នៅតែហ្នឹង ។

ដានី : ដល់ពេល៧៩រត់យ៉ាងម៉េច អ៊ំអាចជួយជម្រាបតិច?

យ៉ន : ពួកហ្នឹងខ្ញុំនៅធ្វើស្រែ ដូចខ្ញុំថាធ្វើស្រែ៥០០ហិចតាហ្នឹង ម៉ននេះគេតាមខ្ញុំទៅ នៅពុស្សរតែ ក្តុងក្តាំង គេរើអីវ៉ាន់រើអី អាខ្លះគេរើកាំបិតអី ខ្ញុំចេញដើរមើលទៅគ្មានស្អីដើរធម្មតា
កាសេតមួយស្ពាយស្អីក៏មិនយកៗមេក្រុមអីនៅស្រែទាំងអស់កុំឲ្យថារត់ចោលគេ កម្លាំងរាប់រយនាក់ ខ្ញុំថា«ឥឡូវខ្ញុំទៅតែម៉ាភ្លែតទេមកវិញ» មកដល់គ្មានស្អីនេះស្ងាត់ឈឹង «មកអូ! គេរត់ចោលអស់រលីងមេឯង នៅតែមីងនៅ» គ្រួសារខ្ញុំគេយកដាក់នៅត្រង់សេរ ។ ខ្ញុំនៅតែភ័យអី តែអ្នកណាធ្វើល្អវាមិនចេះងាប់ ។

ដានី : អូ! ម៉េចទៅចឹង?

យ៉ន : ដល់នេះគេជួយជញ្ជូនអីវ៉ាន់ខ្ញុំ «ដល់នេះទៅសម្រាកលានយើង ថ្ងៃនេះបោកស្រូវជាអង្ករ តែឥឡូវសុំកាប់ជ្រូកកាប់អីហូបហើយ» ។ «អូយ! កាប់ៗទៅដឹណាក់កាលនេះហើយ វាល្មមកាប់ទៅ» ក៏គេជួយការងារបាន ពរកូនខ្ញុំមកដេកនៅលានស្រូវ ។

ដានី : ដេកនៅណា?

យ៉ន ៖ ដេកនៅលានស្រូវ ។

ដានី ៖ លានស្រូវនៅណា?

យ៉ន ៖ នៅខាងក្រោយគុល ។

ដានី ៖ ខាងក្រោយគុល យួនចូលមកហើយ?

យ៉ន ៖ បាទ! ចូលហើយ ។ ខ្ញុំឆ្លងទម្រាំនឹងរួច យើងតគោក្បាលខ្មោចឆ្លងបានធ្លាក់មកអន្លង់វុន យើងរមកកំពីងពួយ ។

ដានី ៖ ហើយម៉េចទៀតទៅ?

យ៉ន ៖ ហ្នឹងមករហូតមកដល់ហ្នឹងម៉ង មករហូត ។

ដានី ៖ រហូតមកដល់ហ្នឹង?

យ៉ន ៖ បាទ!

ដានី ៖ មកជួបតាទិតអីនៅណា?

យ៉ន ៖ នោះកាលហ្នឹងដំណើររត់ហ្នឹង វាមិនគោលដៅនៅនេះទេ ដូចខ្ញុំប្រាប់ចឹង តែរត់ទៅជួបតាម៉ុកនៅស៊ីងលាច ។

ដានី ៖ ស៊ីងលាចនៅណា?

យ៉ន ៖ បាទ! ស៊ីងលាចយើងពោធិ៍សាត់ហ្នឹង ។

ដានី ៖ ពោធិ៍សាត់នោះវិញ?

យ៉ន ៖ បាទ! លាចហ្នឹងខេត្តពោធិ៍សាត់ហើយ ។

ដានី ៖ រត់បកទៅក្រោយវិញ ចឹងមិនមែនរត់មក?

យ៉ន ៖ ផ្លូវជាតិ ផ្លូវ៥៦ កន្លែងលាចពោធិ៍សាត់ ។

ដានី ៖ ខាងជួរ ខាងកោះក្រឡអីហ្នឹង ផ្លូវទៅខាងសំឡូត ខាងអីវិញ?

យ៉ន ៖ បាទ! ហួសទៅហ្នឹងទៀតណាំក្នួយ ផ្លូវហ្នឹងទៅកោះកុង ។

ដានី ៖ អូ! ទៅកោះកុង ។ ហើយម៉េចទៅអ៊ំ បានដល់?

យ៉ន ៖ ដល់ហ្នឹងមកជួបតាម៉ុកៗថាត្រឡប់មកស្រុកបវេលវិញ ។ នាំគ្នាត្រឡប់មកវិញមក ចេះតែមកៗទាល់តែមកដល់នេះ ។

ដានី ៖ មកដល់នេះឆ្នាំណា?

យ៉ន ៖ មកដល់ហ្នឹង៧៩ ។

ដានី ៖ មកដល់កំរៀង?

យ៉ន : មកដល់កំរៀន៧៩ដែរហ្នឹងលោកក្មួយ យើងថ្ងៃ៧មករា ៧៩ដដែល ។

ដានី : ចឹងអ៊ំមានចូលទៅទឹកដីថៃ?

យ៉ន : អត់ទេ លោកក្មួយ មកបានដឹកយកមកដាក់វត្ត មកឡើង ។

ដានី : អ្នកណាដឹកមក?

យ៉ន : ទាហានថៃ ។

ដានី : ទាហានថៃ យើងចូលទៅវាដឹកមកដាក់ហ្នឹងឲ្យ?

យ៉ន : បាទ!

ដានី : ចូលទៅដីថៃកន្លែងណាបានគេដឹក?

យ៉ន : ទាហានថៃ យី!បែបសុទ្ធតែជាចៅហ្វាយខេត្តហើយ.........ខ្ញុំមិនដឹងណាថាម៉េចផង ព្រោះខ្ញុំមានកាំភ្លើង ។ ហើយខ្ញុំមានគោៗខ្ញុំម៉ានឹម ។ ខ្ញុំវ៉ៃកាត់ចែកគេ គេថា«សណ្ដានចិត្តល្អវ៉ៃកាត់ចែកសាច់គេស៊ី» ។ ចុះគោរួមមិនបែងចែកគេស៊ី ហើយពួកថៃក៏មិនដឹង ។ ហើយចូលទៅចចារគេ ខ្ញុំចូលដីគេហ្នឹងចចារនៅមាត់អូរហ្នឹង គេថា«ពួកអ្នកឯងប្រាប់កូនចៅស្អែកខ្ញុំយកឡានមកដឹក រៀបចំដាំបាយអីគ្រប់គ្នាទៅ ប្រហែលជាម៉ោង១ទៅម៉ោង២» ។

ដានី : ដឹកពីកន្លែងណាទៅ?

យ៉ន : ដឹកពីជិតប៉ៃលិននោះលោកក្មួយ ។

ដានី : អូ! ជិតប៉ៃលិន?

យ៉ន : បាទ!

ដានី : ហើយដឹកយកមកដាក់នៅណា?

យ៉ន : នេះដាក់វត្តខ្លែមយើងនេះ ។

ដានី : អូ! ចូលមកដល់វត្តខ្លែម មកដល់ហ្នឹងអ៊ំធ្វើអីទៀត ចាប់ផ្ដើមធ្វើអីទៀត?

យ៉ន : មកដល់នេះ?

ដានី : បាទ!

យ៉ន : មកដល់នេះអត់ទាន់នឹកទេក្មួយ នៅព្រៃសំបើមណាស់ រត់ភៀសដីថៃហើយបេះតែទៅហើយ ។ គេផ្សាយអាមេរិចផ្សាយ ប៉ះអំពៅថៃស៊ីអំពៅថៃ ម៉ាប្រាវៗដូចសត្វចម្រិត ដូចសត្វចឹង កាលនឹងអាមេរិចផ្សាយ ។ ចូលស៊ីៗលែងគិត ម៉ាម្នាក់ម៉ាបាញ់ៗរាប់ហិចតាទាំងអស់ ផ្សាយដល់អាមេរិច ។

ដានី : ចឹងកាលពេលនេះ អឺ!ម៉េចទៅយើងរៀបចំកងទ័ពកងអីឡើងវិញ យ៉ាងម៉េចទៅ?

យ៉ន ៖ បាទ! មកដល់ហ្នឹងចាប់ផ្ដើមពង្រឹងហើយ មានកន្លែងថាត្រូវនៅហ្នឹងហើយគ្មានទៅណាទេ កាប់ឆ្ការព្រៃទៅធ្វើជារោងជាអីនៅទៅ យើងមានពង្រឹងកងទ័ព ព្រោះកាលនឹងវាដាច់អត់មានណាអគ្គភាព ណាអីទេ ចេះតែទៅហើយ ដឹងអាណាទប់អាណាទេ បើខុសគ្នាអត់មានហ៊ាននិយាយគេទេ សុទ្ធតែកាំភ្លើង ។

ដានី ៖ ចុះអ៊ំបានធ្វើអីវិញទៅ?

យ៉ន ៖ ខ្ញុំមកដល់នេះញាកងទ័ពទៀត ។

ដានី ៖ កងទ័ព មានតួនាទីអីដែរ?

យ៉ន ៖ ខ្ញុំមកដល់នេះ នៅខាងកាំភ្លើងធំម្ដងវិញហើយ លែងធ្វើរដើងហើយ ។

ដានី ៖ ខាងអីគេអាហ្នឹង កងវរៈ?

យ៉ន ៖ បាទ! នៅដាប់ជាមួយកងពល ។

ដានី ៖ ឋានះស្មើអីគេ?

យ៉ន ៖ បាទ! ខ្ញុំមកដល់នេះកងវរយទៀត ។

ដានី ៖ ដាប់កងពលវិញ?

យ៉ន ៖ បាទ! នៅជាមួយកងពល គានី កនវិញហើយ ។

ដានី ៖ នៅជាមួយគានី កន?

យ៉ន ៖ បាទ!

ដានី ៖ កងពលលេខប៉ុន្មាន?

យ៉ន ៖ ៣២ ។

ដានី ៖ កងពល៣២? ៣២០ ៣២?

យ៉ន ៖ បាទ! អឺ! កាំភ្លើងខ្ញុំមិនមែន៣២០ទេ ដាប់តាកនម៉ង ។

អ្នកជិតខាង ៖ ដាប់តាកន ២៥០ ។

ដានី ៖ ២៥០ តាកន? ចឹងអ៊ំនៅជាមួយតាកន?

យ៉ន ៖ អត់ទេ តែវាដូចជានៅដែរ ការពារកងពល ។

ដានី ៖ នៅណា នៅម្ដុំណា?

យ៉ន ៖ យើងនៅម្ដុំយើងចក្រីនេះលោកក្មួយ ។

ដានី ៖ កន្លែងចក្រី?

យ៉ន ៖ បាទ!

ដានី ៖ ផ្លូវចូលមក ។ ចឹងម៉ាអាហ្នឹងគេហៅកងពលអី?

យ៉ន ៖ ២៥០ ។

ដានី ៖ ២៥០ តាកនគាត់ធ្វើប្រធានកងពល?

យ៉ន ៖ បាទ! ធ្វើប្រធាន ។

ដានី ៖ អនុ បន្ទាប់ៗពីតាកន ឈ្មោះតាអីខ្លះ?

យ៉ន ៖ ខ្ញុំច្រើនណាស់ ។

អ្នកជិតខាង ៖ តាសារឿន តាពុធ ។

ដានី ៖ ឈ្មោះតាសារឿន ឌុល សារឿននេះ?

យ៉ន ៖ រឿនហ្នឹងកូនប្រសារតាម៉ុកមួយ ហៅ៦៣ ។ កងពលហ្នឹងមានតាសារឿនៗហ្នឹង រឿន៦៣ តាកន៦៤ ។

ដានី ៖ លេខៗគាត់ រឿន៦៣ តាកន៦៤ ។ ចុះតាពុធ?

យ៉ន ៖ ពុធកាលហ្នឹងមិនទាន់បានកងពលឡើយផង គាត់នៅវរសេនាធំ... ។

ដានី ៖ បាទ! ចុះសុន សេន គាត់នៅហ្នឹងដែរ?

យ៉ន ៖ តាសុន សេន កន្លែងគាត់នៅនេះ អូរណាំងយើងនេះ?

ដានី ៖ អូរណាំង?

យ៉ន ៖ បាទ!

ដានី ៖ នៅហ្នឹងចឹងមានតែម៉ាកងពលទេ?

យ៉ន ៖ នេះមានប៉ុន្មានកងពល ៣២០ ២៥០ ។ ដូចពាកងពល ។

អ្នកជិតខាង ៖ ដូចតាសៀន តាភាព ។

ដានី ៖ កាលហ្នឹងយើងយ៉ាងម៉េចទៅ ដូចយើងមានកងពលមានអីហើយ យើងដូចថាកាលហ្នឹងធ្វើសង្គ្រាមយ៉ាងម៉េច?

យ៉ន ៖ យើងកាលហ្នឹង យើងអនុវត្តយកកម្លាំងយើងតិច កម្លាំងតិចអត់ទាន់បានប្រមូលផ្តុំច្រើនទេ អនុវត្តសង្គ្រាមឈ្លប យកកម្លាំងតិចទៅវ៉ៃកម្លាំងធំ វ៉ៃដល់ប្រើប្រាស់ដាក់មីនប្រឆាំងអាត្រាក់អីចឹងទៅ កម្លាំងនៅតិច អត់ទាន់មានកម្លាំងទៅវ៉ៃបុកគ្នាបានទេ ចឹងបានឈ្មោះប្រវត្តិសង្គ្រាមឈ្លប ។

ដានី ៖ ធ្វើសង្គ្រាមឈ្លប?

យ៉ន ៖ បាទ! ទ័ពព្រៃ ។

ដានី : កាលនោះហូបចុកអីយ៉ាងម៉េចវិញ?

យ៉ន : ហូបចុកអត់ចោលទេលោកក្មួយ ចុះខាងអង្គការមនុស្សធម៌ដឹកមកទាំងឃ្លាំងមិនចេះខ្វះៗ ។

ដានី : អូ! អត់ខ្វះហូបទេ?

យ៉ន : អត់ខ្វះទេ គ្រាន់តែ៧៩មកដល់នេះភ្លាម គឺឃ្លាំងឡានមកដល់ភ្លែត អង្ករមកអ្នកពីក្នុងមក ។

ដានី : អត់ពិបាកទេ?

យ៉ន : បាទ! អត់មានពិបាកដាច់អង្ករដាច់អីទេ គឺឡានមកដល់គ្រាន់តែឃើញកម្លាំងឡានមកដល់ភ្លាម ។

ដានី : ចឹងយើងនៅហ្នឹងរហូតហើយក៏មានយួនវ៉ៃចូលមកដល់ហ្នឹងដែរ?

យ៉ន : ចូល ដល់ចឹងទៅយើងទៅនៅដីថៃ ។

ដានី : នៅយូរដែរ?

យ៉ន : យើងយកមីងៗទៅ ជួរដីគេដាក់សង់រោងសង់អីនៅ តែប្រុសៗយើងមកនៅការពារនេះ ។

ដានី : ប៉ុន្មានឆ្នាំទៅបានវ៉ៃយកវិញបាន?

យ៉ន : ម៉ាការៗក្មួយ វាយុទ្ធនាការឆ្នាំ៨២ម្តង ៨៥ម្តង ។

ដានី : ៨៥ដល់ឆ្នាំណាបានយួនចេញ?

យ៉ន : ៨៥ហើយ អូ!អាហ្នឹងវ៉ៃនៅថាយួនដកៗទៅៗហ្នឹងវ៉ៃយូរ ។

ដានី : យូរ?

យ៉ន : ទាល់តែអ៊ុនតាក់មកហើយហ្នឹងក៏នៅដែរ អត់ឡើងទេ ។

ដានី : យូរដែរ?

យ៉ន : បាទ! នៅវ៉ៃយូរដែរ បើថាដកៗទៅ អត់ទេនៅតែវ៉ៃចឹង ។ វ៉ៃដល់ចប់ៗនៅប៉ៃលិនម៉ង អស់ចំនុច ។

ដានី : ឆ្នាំណាវ៉ៃអស់ប៉ៃលិន?

យ៉ន : ពីដើមចូល៩០ប៉ុន្មានទៅហើយ ។

ដានី : ចុះកាលដំបូងនៅហ្នឹងមានផ្ទះមានអីនៅហ្នឹងហើយ?

យ៉ន : បាទ! ផ្ទះមួយៗលោកក្មួយ មានផ្ទះពួកខ្ញុំចាស់ៗតាមកង ។

ដានី : កាលពីជំនាន់តស៊ូ នៅនេះសុទ្ធតែព្រៃ?

យ៉ន : បាទ! ព្រៃ អើតមើលចេះមិនឃើញទេ ព្រៃឫស្សី វាព្រៃឈើ ។

ដានី : ចុះមានមីនមានអីទេ កាល...?

យ៉ន : អឺ!មីនដល់ហើយលោកក្មួយ ដីតាមនេះវ៉ាន់សុទ្ធតែមីន ។

ដានី : យើងដោះខ្លួនឯង?

យ៉ន : បាទ! យើងដោះខ្លួនឯង តែមីននោះ វាមិនមែនអាមីននេះ យើងមីនសុទ្ធមីនអា៦៩ យើងដាក់ហើយមានគ្រាប់ចឹងទៅ កាលណាភ្លើងព្រៃឆេះមកវាអាចរួញម្ចុរចឹងទៅគ្រាន់ផ្ទុរដែរ ។

ដានី : មីនហ្នឹងខាងយើងដាក់ ហើយក៏ខាង?

យ៉ន : ខាងយើងដាក់ ដល់ទៅខាងចំងាយនេះ ហៅថាក-៥នេះ បានខាងយើងគេលែងដាក់ វៀតណាមគេដាក់វិញ ។

ដានី : ដោះអស់ដែរ?

យ៉ន : ដោះអស់ហើយ ។

ដានី : អស់ហើយ?

យ៉ន : បាទ! ស៊ីម៉ាក់ដោះអស់ ។

ដានី : ឥឡូវអស់ហើយនៅស្រុកយើងលែងមានមីនហើយ ។ ចុះនេះសមាហរណកម្មពេលណា?

យ៉ន : សមាហរណកម្មយើង៩៦ ។

ដានី : ខែប៉ុន្មាន?

យ៉ន : ខ្ញុំភ្លេច ។

អ្នកជិតខាង : ខែ៧ ខែ៨ ។

ដានី : ខែ៧ ខែ៨?

អ្នកជិតខាង : ខែ៧ខាងត្បូងធ្វើ បើខែ៨ ។

ដានី : សមាហរណកម្មខាងក្រោយប៉ៃលិន?

យ៉ន : បាទ! ខាងប៉ៃលិនគេធ្វើមុនៗ តែហ៊ើ!កាលហ្នឹងដំណើរការដឹកនាំវាមិនសូវល្អ ។ មកដល់សន្តត់ពួកនេះ ពួក២៥០ខ្ញុំនេះមកដល់សុទ្ធតែរថក្រោះ ប៉ៃលិនមកគៀបខ្ញុំនេះ គៀបសមា ហរណកម្មមុន ហើយពីហ្នឹងមកគេប្រើរថក្រោះអីមកៗបង្ក្រាប២៥០នេះ ដល់ធ្វើចឹងដូច ....មិនកើតអីទេ ក៏ពុធអីវីងបណ្តោយទៅឡើងទៅដល់ជួបសម្តេចផ្ទាល់តែម្តង អត់នៅជា មួយតាអ៊ីឈានទេ ។ ទៅផ្ដាច់ដូចគ្នាម៉ង់មើល ។

ដានី ៖ ខាងម៉ាឡៃមកដែរ?

យ៉ន ៖ មកឡូចូលនេះ ចុះដូចជាស្អីមកគ្រប់គ្រង ថាដូចជា១០ប៉ុន្មាននេះ ខ្ញុំថា១០ប៉ុន្មានទៅទៀត ពួកនេះដាក់កាំភ្លើងមកវៃគ្នា ។ កាលហ្នឹងតាកនអីនៅបញ្ឆាដែរ ហើយតាផានអីផងចង់វៃវិញ រកត្រឹមវៃខ្ទេចខ្ទីអស់ហើយ ។

ដានី ៖ ខាងម៉ាឡៃ ប៉ៃលិនគេផ្ដាច់មុន?

យ៉ន ៖ បាទ! ខាងប៉ៃលិនរាគត្បាតកិនមែនទែនមកដល់ដាក់កងពលអី ថាអួយ!គ្នាឯងមកជិះជាន់គ្នាឯងយ៉ាប់បណ្ដោយថាចេញស្អីៗចេញមិនរួចចឹងមិនបាច់ទេ អត់ទៅនៅជាមួយទេ ។

ដានី ៖ ទៅជួបសម្ដេចផ្ទាល់ម៉ង?

យ៉ន ៖ ជួបសម្ដេចផ្ទាល់និយាយគ្នាឡើងទៅរ៉ាប់ មានអីសម្ដេចហៅបងពុធនេះបាត់ ។

ដានី ៖ ចុះតាកនគាត់នៅណាឥឡូវ?

យ៉ន ៖ គាត់បែបធ្វើចំការហើយ ខ្ញុំ ។

អ្នកជិតខាង ៖ គាត់នៅខាងសំពៅលូន ។

ដានី ៖ គាត់អត់ធ្វើអីទេ ឥឡូវ?

យ៉ន ៖ បាទ! ធ្វើចំការ ។

អ្នកជិតខាង ៖ ទីប្រឹក្សាសម្ដេច ។

ដានី ៖ ទីប្រឹក្សាសម្ដេច?

យ៉ន ៖ អឺ! ទីប្រឹក្សា ។

ដានី ៖ គាត់ត្រូវជាម៉េចតាសុន សេន?

យ៉ន ៖ ត្រូវជាប្អូន តាសុន សេន ។ ប្អូនចិញ្ចឹមទេ តាមមើល ។

ដានី ៖ ប្អូនចិញ្ចឹម ។ ចុះអ៊ំបើតាមបទពិសោធន៍ជីវិតអ៊ំដូចថាអ៊ំធ្លាប់ឆ្លងកាត់ច្រើនរបប តាមពីរបបសម្ដេច របបលន់ នល់ របបពាឆ្នាំ ក្នុងសម័យសង្គ្រាម ហើយក្រោយសមាហរណកម្មអ៊ំគិតមើលថាម៉េចដែរ ការរស់នៅ?

យ៉ន ៖ ខ្ញុំយើងឃើញ ហ៎!មកដល់សម័យយើងឥឡូវនេះ វាឃើញថាពីមុនមកខុសប្លែកគ្នា ។

ដានី ៖ ខុសប្លែកម៉េចទៅ?

យ៉ន ៖ ឥឡូវយើងវារីកចំរើនដូចសម្ដេចថាអភិវឌ្ឍទៅ យើងឃើញពីដើមនៅកន្លែងនេះ សូម្បីតែផ្ទះវាមានតិច ។ ឥឡូវនេះវាកើតទៅជាផ្ទះថ្ម ផ្ទះអីចឹងប្លែកច្រើន ខុសប្លែកពីគ្នាគិត កាលពីជំនាន់មួយវាសង្គ្រាម ។ អានេះយើងចប់សង្គ្រាមហើយ យើងអភិវឌ្ឍទៅ ។

ដានី :	ចុះកាលសម័យ៣ឆ្នាំៗ ហើយឥឡូវ?

យ៉ន :	សម័យ៣ឆ្នាំ វាជួនហ្នឹងការលំបាកច្រើនណាស់លោកក្មួយ ទាំងការងារមិនសូវ លំបាកៗណាស់ ជិនាន់ៗ

ដានី :	ចុះមាន បើអ៊ំធ្លាប់គ្រប់គ្រងអីចឹង ដូចថាការសម្លាប់ការអីដូចគេនិយាយចឹងមែន ឬយ៉ាងម៉េច?

យ៉ន :	ទេ! ខ្លះក៏មាន ខ្លះក៏វាមិនមាន ខ្លះក៏មានខ្លះចឹងទៅដោយសារ ដូចថាខ្ញុំថាចឹងវាមានកំហុសខ្លួនឯងគេចាប់ទៅវាមាន ខ្លួនយើងវាធ្វើខុស គេមិនមែនចេះតែចាប់ៗអត់ហេតុផលៗ ប៉ុន យើងខុសមែនខ្លះ ហើយខ្មែរក្រហមច្បាប់ចឹងហើយ តែសីលធម៌ហើយកម្រហ្នឹងរស់ណាស់ អ្នកឯងមានប្រពន្ធហើយ ចុះម៉េចស្រឡាញ់គេទៀត នឹងអត់ទេ ហ្នឹងតុលាការប្រជាពលរដ្ឋ ដាក់ ងាប់ហើយ ព្រោះអាហ្នឹងច្បាប់ចឹង សីលធម៌តែម៉ាម៉ាត់នេះអត់បាន តែខុស គឺ ងាប់ៗ

ដានី :	ចុះអ៊ំខស្សាហ៍ទៅលេងស្រុកទេ?

យ៉ន :	បាទ! ខ្ញុំទៅបាន២-៣ដងដែរលោកក្មួយៗ

ដានី :	ម៉េចដែរទៅស្រុកអ៊ំ ទៅអ្នកស្រុកអីយ៉ាងម៉េច នៅស្គាល់អ៊ំ រាក់ទាក់អីដែរ ឬក៏មិនសូវទេ?

យ៉ន :	អូ! មកដល់ជួបភ្លាមសុទ្ធតែអ្នកលំបាកដូចគ្នាហ្នឹង សុទ្ធតែរែកដីរែកគ្នាហ្នឹង ហើយថា«ឯងងាប់បាត់ហើយ»អញថា«ឯងងាប់ដូចគ្នា ឯងក៏វែអញៗក៏វែឯងក្តុងក្តាំង» ៗ

ដានី :	អត់អីទេ នៅរាប់អានគ្នាធម្មតា?

យ៉ន :	បាទ!

ដានី :	ចុះអ៊ំនៅស្រុក ហើយនៅនេះនៅខាងណាមានសាច់ញាតិច្រើនជាង?

យ៉ន :	ខាងនេះ នៅនេះដល់ចឹងលោកក្មួយអើយ តាំងពីអ្នកមកនៅពីក្នុងបងប្អូនវាដូចជាមិត្តអស់ ហើយការងារសាមគ្គីគ្នាអី ដូចជាការកូនអីចឹងសុទ្ធតែមនុស្សហៅរាប់រយអីចឹងទៅ ចុះគេស្គាល់ៗគ្នាចឹងទៅៗ ដូចជាបងប្អូនគ្នាអស់ហើយ និយាយរួមម៉ាភូមិដូងអីចឹង ភូមិគេផ្សេង មានការប្រាស្រ័យទាក់ទងគ្នាចឹង រាប់អានគ្នាចឹង មានពេលរវល់អីចឹង យើងក៏ហៅគេៗក៏ហៅយើងទៅ វាញឹក...ៗ កាលមុនគ្នាតិច ដល់គ្នាច្រើនកាន់តែគ្នាច្រើនៗ

ដានី :	ដល់ពេលនៅស្រុកភូមិឥឡូវ ម៉េចដែរ?

យ៉ន :	អ្នកស្រុកភូមិយើងនេះ?

ដានី ៖ អ្នកស្រុកភូមិ ស្រុកកំណើតអ៊ំ?

យ៉ន ៖ អូ! អ្នកស្រុកភូមិស្រុកកំណើតលោកក្មួយ ក៏អត់អីដែរ តែគ្រាន់យួងបែកមកនៅក្នុងឆ្នាំចឹងទៅ វា៣០-៤០ឆ្នាំទៅ ខាងក្រោយៗសូម្បីតែសាច់ញាតិយើងក៏គេអត់មានចាស់ៗ ប្រាប់ អត់ស្គាល់ទេ។

ដានី ៖ អត់ស្គាល់?

យ៉ន ៖ បាទ! ស្គាល់តែម៉ាស្រុកខ្ញុំ គេស្គាល់។

ដានី ៖ អ៊ំទៅលេងស្រុកបានប៉ុន្មានថ្ងៃដែរ?

យ៉ន ៖ ខ្ញុំទៅត្រឹមម៉ាអាទិត្យ ទៅចោលកន្ទែងមិនកើត។

ដានី ៖ ដល់ពេលម៉ាអាទិត្យអីត្រូវមកផ្ទះវិញ?

យ៉ន ៖ បាទ! មកវិញៗ តែបើគេរវល់ការងារ ការកូនអីចឹងទៅ គេហៅយើងគេគេស្ដប្រាប់ចឹងទៅៗ ធ្វើបុណ្យអីជួបជុំគ្នាទៅម៉ាពេលទៅ។

ដានី ៖ មានបងប្អូននៅនឹងដែរ?

យ៉ន ៖ បាទ! បងប្អូនបង្កើតនៅហ្នឹងសុទ្ធតែស្រី តែមានបងថ្លៃ មានប្អូនថ្លៃនៅពួក ក្មួយៗមាន។

ដានី ៖ ចុះអ៊ំមួយទៀតសំនួរខ្ញុំចុងក្រោយអ៊ំដូចជាឥឡូវនេះ នៅខាងរាជរដ្ឋាភិបាល-អង្គការសហប្រជាជាតិ គេបង្កើតតុលាការកាត់ទោសមេដឹកនាំជាន់ខ្ពស់មេដឹកនាំខ្មែរក្រហម។ បើតាមចិត្តអ៊ំផ្ទាល់ អ៊ំយល់ឃើញម៉េចដែរ? គេកាត់ទោសដូចឥឡូវនេះគេកាត់ទោសឌុចដែលជាអតីតប្រធានមន្ទីរស-២១គុកទួលស្លែង កាត់ទោសហើយ។ ហើយខាងមុខនេះគេនឹងកាត់ទោសមេដឹកនាំជាន់ខ្ពស់៤រូបទៀតដូចជា ខៀវ សំផន, នួន ជា, អៀង សារី និងប្រពន្ធរបស់គាត់ បើតាមយោបល់របស់អ៊ំផ្ទាល់ ការយល់របស់អ៊ំៗយល់ឃើញថា ការកាត់ទោសហ្នឹងវាយ៉ាងម៉េចដែរ?

យ៉ន ៖ បាទ! បើខ្ញុំបានស្ដាប់មើលទៅការកាត់ទោសនោះ ព្រោះគាត់ក៏ គាត់ដឹងថាខុសដែរ។

ដានី ៖ គាត់ខុសដែរ?

យ៉ន ៖ ប៉ុននឹកឃើញថាវាសមនឹងយុត្តិធម៌របស់គេមែន។

ដានី ៖ យុត្តិធម៌?

យ៉ន ៖ ដូចថាតុលាការគេមានយុត្តិធម៌ដែរ កាត់ទៅតាមកំហុសដែលគាត់បានធ្វើ ខ្ញុំអត់មានបញ្ហាថា អត់ត្រូវអីដែរ ធម្មតា គេអ្នកកាន់ទោសនេះ ត្រឹមត្រូវ។

ដានី ៖ បាទ! ចឹងខ្ញុំអស់ដូចជាអស់សំនួរត្រូវសួរនាំអ៊ំទៀតហើយ អ៊ំមានអីចង់បន្ថែមនូវអ៊ីដែលខ្ញុំ អត់បានសួរនាំអ៊ំដែរ?

យ៉ន ៖ ខ្ញុំដូចមិនមានអី ។

ដានី ៖ បាទ! ចឹងខ្ញុំអរគុណអ៊ំច្រើន ។

«ចប់»